ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់ សហគ្រាសធុនតូច និងមធ្យម

THE IMPORTANCE OF CAMBODIAN INTERNATIONAL FINANCIAL REPORTING STANDARD FOR SMALL AND MEDIUM ENTERPRISES (CIFRS for SMEs)

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់ សហគ្រាសធុនតូច និងមធ្យម

THE IMPORTANCE OF CAMBODIAN INTERNATIONAL FINANCIAL REPORTING STANDARD FOR SMALL AND MEDIUM ENTERPRISES (CIFRS for SMEs)

គ្រូណែនាំ៖ ហ៊ីង សុខសាន្ត

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម**

(CIFRS For SMEs)

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហ៊ឹង សុខសាន្ត

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធសឹងតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវដល់និស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ លោកគ្រូ អ្នកគ្រូ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**គុណ សុខលី**
ID: B22/961



**ធឿន ជាតិជា**
ID: B22/836



**យ៉ែម ថាវី**
ID: B22/847



**ស៊ី វណ្ណះ**
ID: B22/962



**លី លក្ខណា**
ID :B22/960

## សេចក្ដីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្តដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ដាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា បានផ្តល់ទីកន្លែងបណ្តុះបណ្តាលព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូណែនាំ **ហ៊ីង សុខសាន្ត** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាងដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ សូមគោរពថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបាន ខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមរបស់និយ័តករគណនេយ្យនិងសវនកម្ម" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក.ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី.២៩. ខែ.តុលា. ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

គុណ សុខលី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមកនេះ បានឱ្យដឹងថាសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមពិតជាមានអត្ថប្រយោជន៍ណាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការគ្រប់គ្រងពីការធ្វើគណនេយ្យកម្មនៅក្នុងសហគ្រាសស្របតាមសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមដើម្បីបាននូវរបាយការណ៍ហិរញ្ញវត្ថុមួយដែលមានប្រសិទ្ធភាពសម្រាប់អង្គភាពអាជីវកម្មមួយ។ ហើយការរៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុបានត្រឹមត្រូវដែលជួយបង្កើត ភាពតម្លាភាព និងការជឿជាក់ចំពោះភាគីដែលពាក់ព័ន្ធដូចជា អ្នកវិនិយោគទុន អ្នកប្រើប្រាស់ខាងក្រៅ ឱ្យកាន់តែមានទំនុកចិត្តក្នុងការសម្រេចចិត្តចូល វិនិយោគទុនក្នុងអង្គភាពអាជីវកម្ម។

គោលបំណងនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមនេះដើម្បីសម្រួលការគ្រប់គ្រងបង្ហាញពីស្ថានភាពទូទៅពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដល់សហគ្រាសខ្នាតតូច និងមធ្យម។ការរៀបចំស្តង់ដាគណនេយ្យសម្រាប់SMEs គឺដើម្បីធានាថាសហគ្រាសធុនតូចនិងមធ្យមអាចធ្វើការរាយការណ៍ហិរញ្ញវត្ថុបានយ៉ាងមានប្រសិទ្ធភាព ក្នុងការអនុវត្តនិងគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ និងធ្វើឱ្យមានភាពជឿជាក់ពីអ្នក និងអ្នកផ្តល់ហិរញ្ញវត្ថុ។ ការកំណត់ឱ្យមានស្តង់ដាគណនេយ្យនេះ នឹងធ្វើឱ្យប្រទេសនានានៅលើពិភពលោកអាចអនុវត្តរួមគ្នា និងការគណនាតួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដូចជាតួលេខដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍លទ្ធផលជាដើម។ហើយសម្រាប់ការកត់ត្រាគណនេយ្យកម្មរបស់សហគ្រាសវិញគឺតម្រូវឱ្យផ្តោតទៅលើការអនុវត្តស្របតាមក្របខ័ណ្ឌគណនេយ្យពាក់ព័ន្ធផ្សេងៗ។ ពេលដែលការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាតែមួយធ្វើឱ្យភាគីពាក់ព័ន្ធងាយស្រួលក្នុងការធ្វើការពិនិត្យ និងប្រៀបធៀបលើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយទំនុកចិត្ត។ ហើយភាគីពាក់ព័ន្ធទាំងអស់អាចដឹងពីស្ថានភាពរបស់ក្រុមហ៊ុនតាមរយៈការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលក្រុមហ៊ុនបានរៀបចំឡើង ដូចជាស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនមួយ។

តាមការសិក្សាស្រាវជ្រាវបានសង្កេតឃើញថា បច្ចុប្បន្ននេះសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូចនិងមធ្យម គឺអាចរួមបញ្ចូលនូវសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមជាច្រើនដែលទាក់ទងនឹងវិស័យសហគ្រាសធុនតូច និងមធ្យមការអនុវត្តស្តង់ដាគណនេយ្យ។ បច្ចុប្បន្នមានក្រុមហ៊ុនទីប្រឹក្សា ក្រុមហ៊ុនសវនកម្ម និងកម្មវិធីគណនេយ្យជាច្រើនដែលម្ចាស់អាជីវកម្មអាចប្រើប្រាស់ ដើម្បីជាជំនួយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តង់ដា ដែលធានាបាននូវភាពត្រឹមត្រូវ និងការជឿទុកចិត្តបាន។ ដូច្នេះដើម្បីគ្រប់គ្រងអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងធានាបាននូវការរីកចម្រើនបានវែងឆ្ងាយម្ចាស់អាជីវកម្មគួរគិតគូររៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងមានលក្ខណៈស្តង់ដា។

# មាតិកា

ទំព័រ

អារម្ភកថា ............ i
រចនាសម្ព័ន្ធ ............ ii
សេចក្តីថ្លែងអំណរគុណ ............ iii
អំណះអំណាង ............ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ............ v
មាតិកា ............ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ១
១. តើការរៀបចំស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមមានគោលបំណងអ្វី? ...... ២
២. តើសារៈសំខាន់នៃស្តង់ដាគណនេយ្យមានអត្ថប្រយោជន៍អ្វីខ្លះ? សម្រាប់សហគ្រាសធុនតូច និងមធ្យម.. ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ............ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៤.១ ទំហំដែនកំណត់ ............ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ............ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៤

## ជំពូកទី២
## សារៈសំខាន់នៃស្តង់ដាគណនេយ្យ

២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ............ ៥
២.១.១ និយមន័យស្តង់ដាគណនេយ្យ ............ ៥
២.១.២ ប្រវត្តិនៃស្តង់ដាគណនេយ្យ ............ ៥
២.១.៣ ទ្រឹស្តីនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ...... ៦
២.២ គោលបំណងនៃការរៀបចំស្តង់ដាគណនេយ្យ សម្រាប់សហគ្រាសធុនតូច និងមធ្យម ............ ៧
២.២.១ និយមន័យគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ............ ៧
២.២.២ ប្រវត្តិគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ............ ១១
២.២.៣ ទ្រឹស្តីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម ....... ១៣

២.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យ សម្រាប់សហគ្រាសធុនតូច និងមធ្យម........................... ១៣
២.៣.១ និយមន័យការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ........................................................ ១៣
២.៣.២ ប្រវត្តិនៃការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ .........................................................១៤
២.៣.៣ ទ្រឹស្តីនៃការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ .........................................................១៦

## ជំពូកទី៣
## សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

៣.១ ស្ថានភាពទូទៅរបស់និយ័តករគណនេយ្យនិងសវនកម្ម...........................................................១៨
៣.១.១ ប្រវត្តិរបស់និយ័តករគណនេយ្យ និងសវនកម្ម ..................................................១៨
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់គណនេយ្យ និងសវនកម្ម..........................១៨
ក.ចក្ខុវិស័យ ..............................................................................................................១៨
ខ.បេសកកម្ម..............................................................................................................១៩
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់គណនេយ្យនិងសវនកម្ម ...........................១៩
ក. រចនាសម្ព័ន្ធគ្រប់គ្រង.................................................................................................១៩
ខ. តួនាទីគណគ្រប់គ្រង.....................................................................................................១៩
៣.២ គោលបំណងនៃការរៀបចំស្តង់ដាគណនេយ្យ សម្រាប់សហគ្រាសធុនតូច និងមធ្យម ............ ២១
៣.២.១ ដើម្បីសម្រួលការចងក្រង និងរៀបចំរបាយការណ៍ ....................................២១
៣.២.២ លើកស្ទួយការរីកចម្រើន និងការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាមញ្ញ........................២៧
៣.២.៣ ផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធ ..........................................................................២៧
៣.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យ សម្រាប់សហគ្រាសធុនតូច និងមធ្យម........................... ២៨
៣.៣.១.ការរៀបចំ និងបង្ហាញពីសក្ខីបត្រសម្រាប់សហគ្រាសធុនតូចនិងមធ្យម................. ៣០
ក. ការរៀបចំ និងបង្ហាញពីគណនេយ្យកម្ម សម្រាប់សហគ្រាសធុនតូច និងមធ្យម.......... ៣១
ខ.ការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម....... ៣១
៣.៣.២. អត្ថប្រយោជន៍នៃការអនុវត្តស្តង់ដាក្នុងSMEs............................................................៣២
៣.៣.៣.ការគ្រប់គ្រងរបាយការណ៍សម្រាប់SMEs ........................................................... ៣២

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង................................................................................................ ៣៤
៤.២ ការវិភាគលើចំណុចខ្សោយ ............................................................................................ ៣៤

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ......................................................................................................... ៣៥
៥.២ ការផ្តល់អនុសាសន៍ ..................................................................................................... ៣៥
**ឧបសម្ព័ន្ធ**

## ឯកសារយោង

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាក្រុមហ៊ុនមួយចំនួននៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ដោយសារក្រុមហ៊ុនបានធ្វើការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកទៅលើស្តង់ដាគណនេយ្យ។ ការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យដើម្បីឱ្យមានឯកសារលក្ខណៈភាព។ ដើម្បីឱ្យអ្នកវិនិយោគនឹងមានភាពងាយស្រួលក្នុងការវិនិយោគ ឬបណ្តាក់ទុនចូលក្នុងក្រុមហ៊ុន។ ស្តង់ដាគណនេយ្យទាំងនេះត្រូវបានគេបង្កើតឡើងដើម្បីជួយសហគ្រាសម្ចាស់អាជីវកម្មក្នុងការគ្រប់គ្រងទិន្នន័យហិរញ្ញវត្ថុ និងបង្កើតការរួមបញ្ចូលចំណេះដឹងអំពីវិស័យហិរញ្ញវត្ថុដូចជាការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងការចូលរួមក្នុងពាណិជ្ជកម្មនៅក្នុងទីផ្សារអន្តរជាតិបានត្រឹមត្រូវ។

ដូច្នេះសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមមានភាពចាំបាច់ក្នុងការយល់ពីតួនាទីនិងសារៈសំខាន់របស់ស្តង់ដាគណនេយ្យក្នុងការអភិវឌ្ឍ និងគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម។ ស្តង់ដាគណនេយ្យមានអត្ថប្រយោជន៍យ៉ាងខ្លាំងក្នុងការពង្រឹងទៅលើការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ និងធានាថាមានការបង្ហាញព័ត៌មានហិរញ្ញវត្ថុដែលត្រឹមត្រូវ និងមានគុណភាព។ ដោយសារតែស្តង់ដាគណនេយ្យនេះជួយបង្កើនភាពច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការវិនិយោគ បណ្តាក់ទុនចូលក្នុងក្រុមហ៊ុន។ ការស្រាវជ្រាវទៅលើសារៈសំខាន់នៃស្តង់ដាគណនេយ្យ ត្រូវបង្ហាញថាវាអាចធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមអាចអភិវឌ្ឍដោយមានប្រសិទ្ធភាពជាងមុន និងដើម្បីឱ្យមានឯកលក្ខណៈភាព។

ដោយមើលឃើញអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យ ទើបក្រុមយើងខ្ញុំបានលើកយកប្រធានបទមួយស្តីពី"សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម" មកធ្វើការបកស្រាយវែកញែក និងបង្ហាញឱ្យបានច្បាស់ក្នុងគោលបំណងចែករំលែកចំណេះដឹង ការអនុវត្តបន្ថែមអំពីការអនុវត្តតាមស្តង់ដាគណនេយ្យអាចធ្វើឱ្យសហគ្រាសធុនតូច និងមធ្យមមានតុល្យភាពនិងប្រសិទ្ធភាពក្នុងការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវបានសង្កេតឃើញថា បច្ចុប្បន្ននេះសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺអាចរួមបញ្ចូលនូវសារៈសំខាន់នៃស្តង់ដាគណនេយ្យ ជាច្រើនដែលទាក់ទងនឹងវិស័យសហគ្រាសធុនតូច និងមធ្យមក្នុងការអនុវត្តស្តង់ដាគណនេយ្យ។ ការរៀបចំស្តង់ដាគណនេយ្យគឺដើម្បីធានាថាអាចធ្វើការរាយការណ៍ហិរញ្ញវត្ថុបានយ៉ាងមានប្រសិទ្ធភាពក្នុងការអនុវត្ត និងការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុបានយ៉ាងត្រឹមត្រូវ និងធ្វើឱ្យមានភាពជឿជាក់ពីអ្នកវិនិយោគ និងអ្នកផ្តល់ហិរញ្ញវត្ថុ។ មិនតែប៉ុណ្ណោះស្តង់ដាគណនេយ្យអាចធ្វើឱ្យអាជីវកម្មមានទំនុកចិត្តពីភាគីអ្នកចូលរួមដូចជា អ្នកវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន និងជួយពង្រឹងលើការអនុវត្តសារៈសំខាន់នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមឱ្យមានប្រសិទ្ធភាព។

ដូច្នេះស្តង់ដាគណនេយ្យក៏អាចជួយធ្វើឱ្យមានការពង្រឹងលើការអនុវត្តឱ្យមានប្រសិទ្ធភាពជាមួយនឹងការគណនាដែលត្រឹមត្រូវនិងបញ្ជាក់ថាស្ថាប័នអាជីកម្មសម្រាប់អង្គភាពធុនតូច និងមធ្យមនិងមានការអនុវត្តប្រតិបត្តិការស្តង់ដាគណេយ្យដែលប្រកបដោយប្រសិទ្ធភាព។

អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានលើកយកសំណួរមកចោទសួរដូចខាងក្រោម៖

១. តើការរៀបចំស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមមានគោលបំណងអ្វី?

២. តើសារៈសំខាន់នៃស្តង់ដាគណនេយ្យមានអត្ថប្រយោជន៍អ្វីខ្លះ? សម្រាប់សហគ្រាសធុនតូច និងមធ្យម។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវស្តីពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់ សហគ្រាសធុនតូច និងមធ្យមពិចារណាអំពីការអនុវត្ត និងអត្ថប្រយោជន៍នៃការអនុញ្ញាតឱ្យមានសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម( CIFRS For SMEs )ជាក់លាក់សម្រាប់សហគ្រាសធុនតូច និងមធ្យម។ ការស្រាវជ្រាវនេះអាចមានគោលបំណងដូចខាងក្រោម៖

១. បង្ហាញពីស្ថានភាពទូទៅនៃស្តង់ដាគណនេយ្យ

២. ដើម្បីរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម

៣. យល់ដឹងអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់ សហគ្រាសធុនតូច និងមធ្យមរបស់និយ័តករគណនេយ្យនិងសវនកម្ម ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ អ៊ីម៉ែល info@acar.gov.kh គេហទំព័រ www.acar.gov.kh។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដោយផ្អែកទៅលើពេលវេលា ប្រធានបទ និងចំណោទដែលបានចោទសួរខាងលើ ឯកសារដែលក្រុមនាងខ្ញុំមាន និងធ្វើការស្រាវជ្រាវទៅលើទិន្នន័យដែលមាននៅក្នុងកំឡុងឆ្នាំ២០២១របស់និយ័តគណនេយ្យ និងសវនកម្ម។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងនេះ គឺប្រើប្រាស់តាមវិធីសាស្ត្រប្រមូលទិន្នន័យតាមបែបបរិមាណគុណវិស័យដែលជាវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលឯកសារ និងទិន្នន័យជាចម្បងដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងឆ្លើយតបទៅនិងសំណួរស្រាវជ្រាវ៖

សម្រាប់សំណួរទី១ ការប្រមូលទិន្នន័យតាមបែបវិធីសាស្ត្របរិមាណគុណវិស័យការស្រាវជ្រាវធ្វើឡើងតាមរយៈការប្រមូលទិន្នន័យដកស្រង់ចេញពីគេហៈទំព័រនិយ័តករគណនេយ្យ និងសវនកម្ម ឬឯកសារដែលមាននៅក្នុងបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា សៀវភៅទស្សនាវដ្តីលេខ៤ដើម្បីសរសេរចងក្រងឡើងវិញសម្រាប់ក្នុងការយល់ដឹងពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម។

សម្រាប់សំណួរទី២ ការប្រមូលទិន្នន័យតាមបែបវិធីសាស្ត្របរិមាណគុណវិស័យធ្វើឡើងតាមរយៈការប្រមូលទិន្នន័យដកស្រង់ចេញពីគេហៈទំព័រនិយ័តករគណនេយ្យ និងសវនកម្ម និងឯកសារដែលមានក្នុងបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា ដើម្បីយកមករៀបចំ និងចងក្រងក្នុងបំណងយល់ដឹងពីអត្ថប្រយោជន៍ទៅលើសារៈសំខាន់នៃស្តង់ដាគណនេយ្យានាពេលប្រទេសកំពុងអភិវឌ្ឍ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តួនាទីសំខាន់ៗនៃការសិក្សាស្រាវជ្រាវ គឺដើម្បីពង្រឹងចំណេះដឹងដល់និស្សិតឱ្យមានភាពទូលំទូលាយ។ ការស្រាវជ្រាវនេះពិតជាផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន ជាពិសេសចំពោះ៖

### ១.៦.១ ចំពោះក្រុមស្រាវជ្រាវផ្ទាល់

- ជួយបង្កើតចំណេះដឹងជំនាញ និងសមត្ថភាពផ្ទាល់ខ្លួនដោយការផ្សាភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- យល់ដឹងកាន់តែច្បាស់ពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម និងសវនកម្មផ្ទៃក្នុង
- យល់ដឹងពីការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម
- បង្កើនចំណេះដឹងបន្ថែម ទៅលើការសិក្សាស្រាវជ្រាវ និងការសរសេរសារណា
- ពង្រឹងភាពក្លាហានដល់និស្សិតឱ្យមានទំនួលខុសត្រូវ និងភាពរួបរួមសាមគ្គី

### ១.៦.២ ចំពោះស្ថាប័ន

- យល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយ
- យល់ដឹងពីការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុនៅតាមស្ថាប័ន ឬអង្គភាព

### ១.៦.៣ ចំពោះសង្គម

- ផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ
- ចងក្រងជាទិន្នន័យសម្រាប់សិស្សប្អូនសិក្សាស្រាវជ្រាវជាបន្ត

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើងគឺដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់នូវចំណុចនីមួយៗ និងការរាប់បញ្ចូលចំណុចសំខាន់ដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវគោលបំណង វិធីសាស្ត្រ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវសេចក្តីសន្និដ្ឋាន អនុសាសន៍ និងចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សារួចមក ក្រុមយើងខ្ញុំបានបែងចែកចេញជា៥ជំពូកដែលបានរៀបរាប់ដូចជា៖

**ជំពូកទី១៖** សេចក្តីផ្តើម : ជាចំណុចដែលនិយាយសង្ខេបពីលំនាំបញ្ហាគោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហា ឬហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវផងដែរ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី : និយាយបង្ហាញពីនិយមន័យប្រវត្តិសាស្ត្រទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖** លទ្ធផលនៃការស្រាវជ្រាវ: បង្ហាញអំពីស្ថានភាពទូទៅដែលនិយាយទៅលើសារៈសំខាន់នៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមសម្រាប់សហគ្រាសធុនតូច និងមធ្យម

**ជំពូកទី៤៖** ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ: ការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលបានសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ។

**ជំពូកទី៥៖** សន្និដ្ឋាន និងការផ្តល់អនុសាសន៍: សន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលមាននៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# សារៈសំខាន់នៃស្តង់ដាគណនេយ្យ

## ២.១ លក្ខណៈទូទៅនៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

### ២.១.១ និយមន័យស្តង់ដាគណនេយ្យ

គណនេយ្យ គឺជាវិធីសាស្ត្រនៃការធ្វើការវិភាគ កំណត់ វាស់វែង កត់ត្រា ផ្តុំបញ្ចូលគ្នា និងបកស្រាយនូវរាល់ប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មដែលបានកើតឡើងនៅក្នុងអង្គភាពនីមួយៗ ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របទៅនឹងគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់។

ស្តង់ដាគណនេយ្យៈ គឺជាសំណុំនៃគោលការណ៍ និងនិតិវិធីទូទៅដែលកំណត់មូលដ្ឋាននៃគោលនយោបាយគណនេយ្យហិរញ្ញវត្ថុ និងការអនុវត្តក្នុងការរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ[1]។

### ២.១.២ ប្រវត្តិនៃស្តង់ដាគណនេយ្យ

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) បានវិវត្តចាប់តាំងពីការចាប់ផ្តើម ដើម្បីសម្របខ្លួនទៅនឹងទិដ្ឋភាពផ្លាស់ប្តូរនៃហិរញ្ញវត្ថុជាសាកល។ ខាងក្រោមនេះជាទិដ្ឋភាពទូទៅនៃការវិវត្តសំខាន់ៗនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ៖

**១. ប្រវត្តិនិងការបង្កើតដំបូង**

**1973-2000: ស្តង់ដាគណនេយ្យអន្តរជាតិ (IAS)**

- ឆ្នាំ 1973: គណៈកម្មាធិការកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ (IASC) ត្រូវបានបង្កើតឡើងដោយស្ថាប័នគណនេយ្យមកពីដប់ប្រទេស ដើម្បីបង្កើតស្តង់ដាគណនេយ្យអន្តរជាតិ (IAS)
- ឆ្នាំ 1989: IASC បានចេញ "ក្របខ័ណ្ឌសម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលផ្តល់មូលដ្ឋានគ្រឹះនៃគំនិតសម្រាប់បង្កើតស្តង់ដាថ្មី និងវិសោធនកម្មស្តង់ដាដែលមានស្រាប់។

**២. ការផ្លាស់ប្តូរទៅ (IFRS)**

**2001-2005: ការបង្កើត IFRS**

- ឆ្នាំ2001: ក្រុមប្រឹក្សាស្តង់ដាកំណត់គណនេយ្យអន្តរជាតិ (IASB) បានជំនួសពី IASC។ IASB បានចាប់ផ្តើមបង្កើតស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដោយជំនួស IAS ជាមួយ IFRS
- ឆ្នាំ2002: សហភាពអឺរ៉ុបបានសម្រេចចិត្តអនុម័តIFRSសម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីចាប់ពីឆ្នាំ2005តទៅដែលជំរុញយ៉ាងខ្លាំងដល់ការអនុម័ត IFRS នៅទូទាំងពិភពលោក។

[1] KHsearch. គណនេយ្យ. (2019, March 28). *មេរៀនទស្សនៈទានទូទៅអំពីគណនេយ្យ(ភាគ១)*. Retrieved March, 02 2025 from https://www.khsearch.com/qna/18013

## ៣. ចំណុចសំខាន់ និងការកែប្រែ

### 2006-2011: ការបញ្ចូលគ្នា និងការអនុម័តជាសាកល

- ឆ្នាំ2006: អនុស្សរណៈនៃការយោគយល់គ្នារវាង IASB និងក្រុមប្រឹក្សាស្តង់ដាគណនេយ្យ ហិរញ្ញវត្ថុ (FASB) មានគោលបំណងបង្រួបបង្រួម IFRS និង U.S. GAAP
- ឆ្នាំ2011: ប្រទេសជិត 120 បានទាមទារ ឬអនុញ្ញាតឱ្យប្រើប្រាស់ IFRS សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជី។

### 2012-2020: ការពង្រឹងស្តង់ដាថ្មី

- ឆ្នាំ2013: IFRS 13 "ការវាស់វែងតម្លៃទីផ្សារប៉ាន់ស្មាន" ត្រូវបានចេញ ដើម្បីផ្តល់ជាការណែនាំមួយសម្រាប់ការវាស់វែងតម្លៃទីផ្សារប៉ាន់ស្មាន
- ឆ្នាំ2014: IFRS 15 "ចំណូលពីកិច្ចសន្យាជាមួយអតិថិជន" ត្រូវបានចេញ ដើម្បីធ្វើជាស្តង់ដាការអនុវត្តការទទួលស្គាល់ប្រាក់ចំណូល
- ឆ្នាំ2016: IFR16 ត្រូវបានចេញដែលតម្រូវឱ្យអ្នកជួលទទួលស្គាល់ទ្រព្យសម្បត្តិ និងបំណុលសម្រាប់ការជួលភាគច្រើន។
- ឆ្នាំ2018: IFRS 9 "ឧបករណ៍ហិរញ្ញវត្ថុ" និង IFRS 17 "កិច្ចសន្យាធានារ៉ាប់រង" ត្រូវបានអនុវត្តដោយបង្កើនគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យាធានារ៉ាប់រង។

### 2021-បច្ចុប្បន្ន និរន្តរភាព និងរបាយការណ៍ឌីជីថល

- ឆ្នាំ2021: មូលនិធិ IFRS បានប្រកាសពីការបង្កើតក្រុមប្រឹក្សាស្តង់ដានិរន្តរភាពអន្តរជាតិ (ISSB) ដើម្បីបង្កើតស្តង់ដាពិភពលោកសម្រាប់ការបង្ហាញហិរញ្ញវត្ថុដែលទាក់ទងនឹងនិរន្តរភាព។
- កំពុងដំណើរការ: មូលនិធិ IFRS បន្តស្វែងរកការរួមបញ្ចូលនៃការរាយការណ៍ឌីជីថល និងការកែលម្អស្តង់ដា ដើម្បីឆ្លើយតបនឹងការវិវត្តនៃការអនុវត្តអាជីវកម្ម និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា[2]។

**២.១.៣ ទ្រឹស្តីនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម**

ទ្រឹស្តីនៃស្តង់ដាគណនេយ្យហិរញ្ញវត្ថុអន្តរជាតិ (IFRS)គឺជាសំណុំនៃគោលនៃស្តង់ដាគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាកំណត់ស្តង់ដាគណនេយ្យអន្តរជាតិ(IASB1973) IFRS ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជា ស្តង់ដារួមសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ ធានានូវភាពស៊ីសង្វាក់គ្នា តម្លាភាព និងការប្រៀបធៀបនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនៅទូទាំងប្រទេស។

ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IFRS)បង្កើតជាគោលការណ៍សម្រាប់ការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមមាន របាយការណ៍តុល្យការ របាយការណ៍លទ្ធផល របាយការណ៍លំហូរសាច់ប្រាក់ និងរបាយការណ៍នៃការបម្រែបម្រួលភាគហ៊ុនរបស់ម្ចាស់អាជីវកម្ម។ ស្តង់ដាទាំងនេះគ្របដណ្តប់ទៅលើ និយមន័យ ការទទួលស្គាល់ ការវាស់វែង និងការបង្ហាញព័ត៌មានហិរញ្ញវត្ថុ។ គោលដៅរបស់ IFRS គឺដើម្បីបង្កើនគុណភាព ភាពពាក់ព័ន្ធ និងភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុដោយហេតុនេះ វាជួយសម្រួលដល់ការសម្រេចចិត្តកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ក្នុងនោះរួមមានដូចជា៖ ម្ចាស់បំណុល និយ័តករ និង

[2] គី សុភាក់. (ថ្ងៃ០៨ ខែមេសា ២០២៥). *ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ.* ទស្សនាវិជ្ជីវិទ្យាសាស្ត្រលេខ៤ នៃសាកលវិទ្យាល័យវ៉ាន់ដា.ទំព័រទី២ ដល់ទី៤

អ្នកពាក់ព័ន្ធផ្សេងទៀត។ តាមរយៈការលើកកម្ពស់តម្លាភាពនិងការប្រៀបធៀប IFRS រួមចំណែកដល់ស្ថិរភាព និងប្រសិទ្ធភាពនៃទីផ្សារហិរញ្ញវត្ថុពិភពលោកលើកទឹកចិត្តការវិនិយោគ និងជំរុញកំណើនសេដ្ឋកិច្ច។ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ(IFRS) មានសារៈសំខាន់ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលផ្តល់អត្ថប្រយោជន៍ចំពោះក្រុមហ៊ុន និងទីផ្សារលើពិភពលោកផងដែរ[3]។

## ២.២ គោលបំណងនៃការរៀបចំស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

### ២.២.១ និយមន័យគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

គណនេយ្យគឺជាដំណើរការនៃការកំណត់ ការវាស់វែង ការកត់ត្រា ការបញ្ជូន និងការបកស្រាយនូវប្រតិបត្តិការសេដ្ឋកិច្ចរបស់អង្គភាពអាជីវកម្មមួយនូវក្នុងកំឡុងពេលវេលាមួយដ៏ជាក់លាក់[4]។

គោលបំណងរបស់គណនេយ្យ គឺផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ទៅដល់មនុស្សទាំងអស់ដែលមានបំណងក្នុងការវិនិយោគ និងការសម្រេចចិត្តផ្សេងៗទៀត។ គោលបំណងគណនេយ្យក៏បានផ្តល់នូវព័ត៌មានហិរញ្ញវត្ថុយ៉ាងសំខាន់ទៅដល់អង្គភាព អាជីវកម្មមួយដើម្បីជួយពួកគេនូវក្នុងការធ្វើផែនការ និងការត្រួតពិនិត្យសកម្មភាពផ្សេងៗរបស់អង្គភាព។ អ្នកដែលប្រើប្រាស់ព័ត៌មានគណនេយ្យនោះរួមមានដូចជា៖

- អ្នកវិនិយោគបច្ចុប្បន្ន និងអ្នកវិនិយោគសក្តានុពល (Present and Potential Investors )
- ម្ចាស់បំណុល ( Lender )
- អ្នកគ្រប់គ្រងអង្គភាពអាជីវកម្ម ( Manager of Organizations )
- អ្នកផ្គត់ផ្គង់ (Suppliers )
- អតិថិជន (Customers )
- រាជរដ្ឋាភិបាល (Government )
- និងអ្នកប្រើប្រាស់ផ្សេងៗទៀត(Other Consumer )។

- **គុណប្រយោជន៍របស់គណនេយ្យ (Advantages of Accounting )**

គណនេយ្យ គឺជាផ្នែកមួយដ៏សំខាន់ និងបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងខ្លាំងនៅក្នុងការចាត់ចែងការគ្រប់គ្រងអាជីវកម្មពីព្រោះ៖

- វាអាចជួយសម្រួលទៅដល់ការរៀបចំបញ្ជីផ្សេងៗ របស់ក្រុមហ៊ុនឱ្យមានរបៀបរៀបរយ
- បង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីឱ្យអ្នកគ្រប់គ្រង ឬក៏ម្ចាស់ក្រុមហ៊ុនងាយស្រួលនៅក្នុងការរៀបចំនិងចេញសេចក្តីសម្រេចផ្សេងៗ
- បង្ហាញពីស្ថានភាពចំណូល និងចំណាយដែលបានកើតឡើងក្នុងដំណើការ អាជីវកម្ម ដែលវាអាចជួយឱ្យអ្នកគ្រប់គ្រងមានលទ្ធភាពក្នុងការកាត់បន្ថយនូវចំណាយដែលគ្មានប្រយោជន៍មួយចំនួន
- វាជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយសម្រាប់ធ្វើការវិភាគ ការពិចារណាអំពីគោលការណ៍ផែនការ និងការកំណត់នៅទិសដៅផ្សេងៗទៀត

[3] គី សុភាក់. (ថ្ងៃ០៨ ខែមេសា ២០២៥). *ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ.* ទស្សនាវដ្តីវិទ្យាសាស្ត្រលេខ៤ នៃវិទ្យាស្ថាន វ៉ាន់ដា.ទំព័រទី៥ ដល់ទី៦

[4] KHsearch. គណនេយ្យ. (2019, March 28). *មេរៀនទស្សនៈទានទូទៅអំពីគណនេយ្យ(ភាគ១).* Retrieved March, 02 2025 from https://www.khsearch.com/qna/18013

- បង្ហាញពីលទ្ធផលរកស៊ីថា ចំណេញ ឬខាត?
- ជួយដល់អ្នកគ្រប់គ្រង ក្នុងការតាមដានសកម្មភាពអាជីវកម្មរបស់គេ
- អាចកាត់បន្ថយនៅការកេងប្រវ័ញ្ចផ្សេងៗបាន
- ផ្តល់ភាពងាយស្រួលក្នុងការកំណត់មុខងារហិរញ្ញវត្ថុ របស់ក្រុមហ៊ុនសម្រាប់ធ្វើការបង់ពន្ធ និងការធ្វើផែនការហិរញ្ញវត្ថុ។

**ប្រព័ន្ធគណនេយ្យ (Accounting System)**

ប្រព័ន្ធគណនេយ្យ គឺជាប្រព័ន្ធមួយដែលគេប្រើប្រាស់សម្រាប់ការធ្វើការបកស្រាយ ការវិភាគ កត់ត្រា វាស់វែង ចាត់ចំណាត់ថ្នាក់ និងសរុបអំពីទំនាក់ទំនងព័ត៌មានដែលមានអត្ថប្រយោជន៍ដល់អ្នកវិនិយោគ

- ការវិភាគ (Analyze) គឺជាការវិភាគលើសកម្មភាពមួយថាតើសកម្មភាពនោះ កើតឡើងមកពីណា?
- ការកត់ត្រា(Recording) គឺជាការកត់ត្រាអន្តរការ នីមួយៗជាតម្លៃទឹកប្រាក់
- ការវាស់វែង(Measure) គឺជាការវាស់វែងជាតម្លៃទឹកប្រាក់ដែលយើងបាន កត់ត្រាថាតើវាស្មើគ្នា ហើយ ឬនៅវាងឥណពន្ធ(Debit) និងឥណទាន (Credit)
- ការចាត់ចំណាត់ថ្នាក់ (Classifying) គឺជាការចាត់ថ្នាក់អន្តរការទាំងអស់នៃ គណនេយ្យនីមួយៗ ដែលមានឈ្មោះដូចគ្នា ឬលេខដូចគ្នាដាក់ទៅតាមក្រុមនីមួយៗដែលមានទំនាក់ទំនងគ្នា។
- ការសរុប(Summarizing) គឺជាការសង្ខេបព័ត៌មានគណនេយ្យទាំងអស់ ដែលមានសារៈសំខាន់ និងមានប្រយោជន៍ចំពោះអ្នកដែលត្រូវធ្វើការសម្រេចចិត្តក្នុងការរៀបចំរបាយការណ៍ណាមួយដែលយើងចង់បាន។

របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍ផលសម្រេចមួយនៃដំណើការគណនេយ្យដែលគេរៀបចំឡើងនៅចុងការិយបរិច្ឆេទ។ របាយការណ៍ហិរញ្ញវត្ថុ គឺរាយការណ៍រាល់សកម្មភាពដែលទាក់ទងទៅនឹងការប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុហើយវាក៏បង្ហាញពីលទ្ធផលមួយ ដែលក្រុមហ៊ុនសម្រេចបាននូវក្នុងពេលវេលាជាក់លាក់ណាមួយ។ វាក៏ជាមធ្យោបាយមួយនៃការបញ្ជូនចំណេញខាត និងស្ថានភាពហិរញ្ញវត្ថុទៅអ្នកចាត់ចែង និងអ្នកខាងក្រៅដែលមានចំណាប់អារម្មណ៍។ គេប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញពីគោលបំណង និងដំណើការផ្សេងៗដែលកើតមានឡើងនូវក្នុងអង្គភាពហើយក៏ជាឧបករណ៍មួយសម្រាប់វាស់វែង និងវាយតម្លៃលើដំណើរការនៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពសម្រាប់ធ្វើការព្យាករណ៍ និងការធ្វើផែនការយុទ្ធសាស្ត្ររបស់អង្គភាពសម្រាប់ពេលអនាគត។

**គោលបំណងរបាយការណ៍ហិរញ្ញវត្ថុ (The Purpose of Financial Statement)**

គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ គឺផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ ការប្រើប្រាស់ព័ត៌មាន និងការប្រែប្រួលនូវស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយដែលមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ទូទៅ ក្នុងការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ របាយការណ៍ហិរញ្ញវត្ថុនេះក៏បង្ហាញអំពីលទ្ធផលនៃការគ្រប់គ្រងធនធានរបស់អង្គភាពនូវក្នុងការិយបរិច្ឆេទមួយផងដែរ ពោលគឺផ្តល់ព័ត៌មានហិរញ្ញវត្ថុដែលមានប្រយោជន៍ដល់អ្នកវិនិយោគ និងការរកភាពមិនច្បាស់លាស់នៃចលនាសាច់ប្រាក់ និងទង្វើផ្សេងៗរបស់អ្នកគ្រប់គ្រង ។

ដើម្បីសម្រេចបាននូវគោលបំណងទាំងនេះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវផ្តល់នូវព័ត៌មានអំពីអង្គភាពដូចជា៖

- ទ្រព្យសកម្ម
- បំណុល
- មូលធន
- ចំណូល និងចំណាយដែលរួមទាំងចំណេញ និងខាត
- ការប្រែប្រួលផ្សេងៗទៀតក្នុងផ្នែកមូលធន
- លំហូសាច់ប្រាក់របស់អង្គភាព ។

## សារៈសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ (Important Of Financial Statement)

របាយការណ៍ហិរញ្ញវត្ថុ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នកវិនិយោគ ម្ចាស់បំណុល និងអ្នកប្រើប្រាស់ផ្សេងៗ ទៀតពីព្រោះរបាយការណ៍ទាំងនោះវាផ្តល់ព័ត៌មានដែលអ្នកចង់ដឹងថាតើមានសាច់ប្រាក់ប៉ុន្មាន? ហើយត្រូវទទួលសាច់ប្រាក់ទាំងនោះទទួលបានមកពីប្រភពណាខ្លះ ហើយទទួលបានវានៅពេលណា ? នូវក្នុងការវិភាគហិរញ្ញវត្ថុ វាអាចជួយយើងក្នុងការ ៖

- វាយតម្លៃលើហានិភ័យដែលកើតឡើង
- វាយតម្លៃនៅប្រសិទ្ធភាពក្នុងការអនុវត្តន៍ការងាររបស់អ្នកគ្រប់គ្រង
- វាយតម្លៃនូវលទ្ធភាពប្រាក់ចំណេញ លទ្ធភាពបំណុល និងអាចធ្វើការព្យាករណ៍អំពីស្ថានភាពរបស់អង្គភាពសម្រាប់ពេលអនាគត។

## អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ( Users Of Financial Statement)

របាយការណ៍ហិរញ្ញវត្ថុ គឺមានសារៈសំខាន់ជាច្រើនក្នុងការផ្តល់នូវព័ត៌មាន សម្រាប់អ្នកប្រើប្រាស់ និងគ្រប់គ្រងក្នុងការធ្វើការសម្រេចចិត្ត។ ហើយគ្រប់អាជីវកម្មទាំងអស់តែងតែរក្សាទុកនៅការកត់ត្រាគណនេយ្យ ឬឯកសារផ្សេងៗដើម្បីធ្វើជាជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគេ។ អ្នកដែលប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរួមមាន ៖

- អ្នកគ្រប់គ្រងទូទៅ( General Managers )៖ អ្នកគ្រប់គ្រងប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងលើកិច្ចការប្រតិបត្តិការរបស់ក្រុមហ៊ុនដោយធ្វើការវាយតម្លៃលទ្ធផលហិរញ្ញវត្ថុ ដើម្បីឆ្ពោះទៅរកគោលដៅអនាគត និងការសម្រេចចិត្តសំខាន់ៗក្នុងសកម្មភាពអាជីវកម្ម
- ភាគទុននិក( Shareholders )៖ ភាគទុននិកបានប្រើប្រាស់នូវរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃលើហានិភ័យ និងការទទួលបាននូវការវិនិយោគនៅក្នុងក្រុមហ៊ុនរបស់ពួកគេ និងធ្វើការសម្រេចចិត្តវិនិយោគដោយផ្អែកលើការវិភាគ
- អ្នកវិនិយោគ(Investors)៖ អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីវាយតម្លៃអំពីលទ្ធភាពជោគជ័យនៃការវិនិយោគក្នុងក្រុមហ៊ុន។ ហើយអ្នកក៏អាចទស្សន៍ទាយអំពីភាគលាភអនាគតដោយផ្អែកលើប្រាក់ចំណេញដែលបានបង្ហាញនូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ លើសពីនេះទៅទៀតរបាយការណ៍ហិរញ្ញវត្ថុបានផ្សាភ្ជាប់ជាមួយ នឹងកម្រិតហានិភ័យនៃការវិនិយោគដែលអាចទទួលបានមកពីរបាយការណ៍ហិរញ្ញវត្ថុនេះ។ (ហេតុដូច្នេះមានន័យថា ប្រសិនបើប្រាក់ចំណេញធ្លាក់ចុះ

បង្ហាញថាហានិភ័យខ្ពស់ តែប្រសិនបើប្រាក់ចំណេញកើនឡើងនោះហានិភ័យទាប)។ ដូច្នេះ របាយការណ៍ហិរញ្ញវត្ថុបានផ្ដល់នៅមូលដ្ឋានមួយសម្រាប់ការសម្រេចចិត្តក្នុងការវិនិយោគ។

- ស្ថាប័នហិរញ្ញវត្ថុ ( Financial Institutions )៖ ស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីធ្វើការវាយតម្លៃថាតើគួរផ្ដល់ប្រាក់កម្ចី ឬឥណទានឱ្យអាជីវកម្មមួយនោះដែរឬទេ ?ពីព្រោះ មុន នឹងផ្ដល់កម្ចីធនាគារត្រូវប្រមើលមើលលទ្ធភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីដើម្បីប្រឈម មុខនឹងការ សងត្រឡប់មកវិញ។ ការវាយតម្លៃនោះរួមមានការធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកខ្ចី និងការ ព្យាករណ៍ពីប្រតិបត្តិការនាពេលអនាគតរបស់អ្នកខ្ចី។
- អាជ្ញាធរពន្ធដា(Taxing Authorities)៖ គឺប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុក្នុងគោលបំណងដើម្បី កំណត់នូវមូលដ្ឋានគិតពន្ធ។ ពន្ធលើប្រាក់ចំណេញគឺផ្អែកលើតួរលេខជាក់ស្ដែងដែលកើតឡើង នៅក្នុងព័ត៌មានគណនេយ្យដែលបានបង្ហាញ។
- អ្នកផ្គត់ផ្គង់(Suppliers)៖ គឺប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុក្នុងគោលបំណងដើម្បីវាយតម្លៃពី ភាពសាកសមនៃបំណុលរបស់អាជីវកម្មហើយកំណត់សម្គាល់មើលថា តើគួរផ្គត់ផ្គង់ទំនិញជំពាក់ ឬអត់? អ្នកផ្គត់ផ្គង់ចាំបាច់ត្រូវដឹងឱ្យបានប្រសិនបើគេ នឹងសងត្រឡប់មកវិញ។
- អតិថិជន(Customers)៖ គឺប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដើម្បីវាយតម្លៃថាតើក្រុមហ៊ុនផ្គត់ផ្គង់ មានធនធានដើម្បីធានាឱ្យបាននូវស្ថិរភាពនៃការផ្គត់ផ្គង់ទំនិញសម្រាប់នាពេលអនាគតនេះ គឺជា ចំនុចសំខាន់ដែលអតិថិជនពឹងផ្អែកលើក្រុមហ៊ុនផ្គត់ផ្គង់សម្រាប់ជាសមាសភាគឯកទេសមួយ។
- និយោជិក(Employees)៖ និយោជិកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ធ្វើការវាយតម្លៃពី ប្រាក់ចំណេញរបស់ក្រុមហ៊ុន និងលទ្ធផលរបស់ខ្លួនលើប្រាក់ខែ និងសុវត្ថិភាពការងាររបស់ពួក គេនាពេលអនាគត។
- គូប្រកួតប្រជែង(Competitors)៖ គូប្រកួតប្រជែង គឺប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុក្នុងការ ប្រៀបធៀបជាមួយក្រុមហ៊ុនដែលជាគូប្រជែងតាមរយៈការរៀននិងអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីកែ លម្អការប្រកួតប្រជែងរបស់ខ្លួន[5]។

### ២.២.២ ប្រវត្តិគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

ក្រុមប្រឹក្សាជាតិគណនេយ្យសម្រេចជ្រើសរើសសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាស ធុនតូច និងមធ្យមដែលសមមូលទៅនឹងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិដែលចេញផ្សាយ ជាធរមានដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិដែលពីពេលនេះទៅត្រូវហៅថា "ស្តង់ដារបាយការណ៍ ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា" (CIFRS) សម្រាប់អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលនឹងចាប់ ផ្តើមនៅថ្ងៃឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ព្រមទាំងសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហ គ្រាសធុនតូច និងមធ្យមឆ្នាំ២០១២ ដែលសមមូលទៅ នឹងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ ជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានចេញផ្សាយជាធរមានដោយក្រុមប្រឹក្សាស្តង់ដា គណនេយ្យអន្តរជាតិដែលពីពេលនេះទៅត្រូវហៅថាស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃ

[5] KHsearch. គណនេយ្យ. (2019, March 28). *មេរៀនទស្សនៈទានទូទៅអំពីគណនេយ្យ(ភាគ១)*. Retrieved March, 02 2025 from https://www.khsearch.com/qna/18013

កម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមសម្រាប់អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលនឹងចាប់ផ្តើម នៅថ្ងៃ ឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។ សហគ្រាសដែលមានការទទួលខុសត្រូវជាសាធារណៈដែលត្រូវបានអនុវត្តស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ សហគ្រាសអាចអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) មុនកាលកំណត់បាន។

សហគ្រាសដែលតម្រូវឱ្យដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើ សវនកម្មតាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុន្តែមិនមែនជាសហគ្រាសដែលមានការ«ទទួលខុសត្រូវជាសាធារណៈដូចដែលបានឱ្យនិយមន័យនៅចំណុច២ខាងក្រោមត្រូវអនុវត្តស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។ សហគ្រាសទាំងនេះក៏អាចអនុវត្តតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាបានដោយពុំមានការខុសទាស់ឡើយកាលបើសហគ្រាសទាំងនេះយល់ឃើញថាជាការចាំបាច់ក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

សម្រាប់សហគ្រាសដែលមិនមានការទទួលខុសត្រូវជាសាធារណៈហើយមិនតម្រូវឱ្យដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មក៏អាចប្រើប្រាស់ស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមបានដែរ។

**សហគ្រាសដែលមានការទទួលខុសត្រូវជាសាធារណៈ ប្រសិនបើ**

ក-ឧបករណ៍បំណុល ឬមូលធនផ្សេងៗរបស់សហគ្រាសនោះត្រូវបានធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាសាធារណៈ ឬសហគ្រាសដែលកំពុងដំណើរការ នៃការបញ្ចេញនូវឧបករណ៍ទាំងនេះសម្រាប់ធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាសាធារណៈ( ទីផ្សារភាគហ៊ុនក្នុងស្រុក បរទេស ឬទីផ្សារអូធីស៊ី ក្នុងស្រុក ឬក្នុងតំបន់ )

ខ- សហគ្រាសកាន់កាប់ទ្រព្យសកម្មដែលមានកិច្ចសន្យាធានាចំពោះអ្នកដទៃជាច្រើនដែលជាផ្នែកមួយនៃធុរកិច្ចសំខាន់របស់សហគ្រាសដូចជា ធនាគារសហជីពឥណទានក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនជួញដូរមូលបត្រ ក្រុមហ៊ុនជើងសារមូលបត្រ និងធនាគារវិនិយោគ។

សហគ្រាស ឬសាធារណៈជនដែលត្រូវការឯកសារអាចរកបានគ្រប់ពេលម៉ោងធ្វើការលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានទីតាំង ផ្លូវលេខ៩២ សង្កាត់ វត្តភ្នំ ខណ្ឌដូនពេញ ក្រុង ភ្នំពេញ ឬអាចរកបានតាមរយៈគេហទំព័រ www.naccambodia.gov.kh សេចក្តីជូនដំណឹងលេខ ០៤១/០៩ MEF/NAC ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០៩ ត្រូវទុកជាមោឃៈ។

ការមិនអនុវត្តតាមសេចក្តីជូនដំណឹងនេះនឹងត្រូវចាត់ទុកថាជាការល្មើសទៅ នឹងប្រការ៤ នៃប្រកាសលេខ ០៦៨ សហវ-ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ដែលយោងខាងលើ។

អាស្រ័យហេតុនេះ សូមគ្រប់សហគ្រាសដែលជាប់កាតព្វកិច្ចត្រូវអនុវត្តឱ្យបានត្រឹម ត្រូវតាមខ្លឹមសារនៃសេចក្តីជូនដំណឹង នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ[6]។

របាយការណ៍ហិរញ្ញវត្ថុ ជារបាយការណ៍មួយដែលផ្តល់នូវព័ត៌មានទាក់ទងដល់សកម្មភាពអាជីវកម្ម និងព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយដល់អ្នកប្រើប្រាស់ខាងក្រៅដើម្បី ធ្វើសេចក្តីសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច។ ហេតុនេះរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងដោយអាន វិភាគ និងឈានទៅដល់

---

[6] វិទ្យាស្ថាន វ៉ាន់ដា. (បោះពុម្ពឆ្នាំ២០១៣). ផ្នែកទី១១ ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិឆ្នាំ២០០៩ ទំព័រ ១២៣ ដល់ ១២៥

ក្រុមហ៊ុនត្រូវតែមានឯកលក្ខណៈភាពគ្នា និងត្រឹមត្រូវក្នុងគោលបំណងការពារផលប្រយោជន៍អ្នកប្រើប្រាស់ក៏ដូចជាសាធារណៈជនទូទៅ។ ដើម្បីទទួលបានដូចខាងលើក្រុមហ៊ុនត្រូវតែរៀបចំរបាយការណ៍ហិរញ្ញវត្ថុគោរពតាមស្តង់ដាគណនេយ្យ។ ដូច្នេះបណ្តាប្រទេសមួយចំនួនស្ថិតនៅតំបន់អឺរ៉ុបបានមូលមតិគ្នាដើម្បីបង្កើតស្តង់ដាគណនេយ្យអន្តរជាតិមួយផ្សេងពីស្តង់ដាគណនេយ្យអាមេរិកកាំងស្តង់ដានោះមានឈ្មោះហៅថា IFRS សព្វថ្ងៃមានបណ្តាប្រទេសជាច្រើនទូទាំងពិភពលោកកំពុងប្រើប្រាស់ស្តង់ដាមួយនេះ[7]។

**២.២.៣ ទ្រឹស្តីនៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម**

ទ្រឹស្តីនៃសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺជាការបង្ហាញត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុតើការអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមនេះតម្រូវឱ្យធ្វើអ្វី តើអ្វីជាសំណុំពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ។

ការបង្ហាញត្រឹមត្រូវរបាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញដោយត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។ ការបង្ហាញត្រឹមត្រូវទាមទារនូវការបង្ហាញប្រកបដោយការពិតអំពីឥទ្ធិពលនៃប្រតិបត្តិការព្រឹត្តិការណ៍ និងស្ថានការណ៍ដទៃទៀតស្របតាមនិយមន័យ និងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់សម្រាប់ ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។

(ក)ការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមរួមជាមួយការលាតត្រដាងបន្ថែមបើសិនមានការចាំបាច់ត្រូវបានសន្មតថានាំឱ្យមានរបាយការណ៍ហិរញ្ញវត្ថុ ដែលសម្រេចបានការបង្ហាញត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុលទ្ធផលហិរញ្ញវត្ថុ លំហូរសាច់ប្រាក់របស់អង្គភាពធុនតូច និងមធ្យម។

(ខ) ការអនុវត្តស្តង់ដានេះដោយអង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈមិននាំឱ្យមានការបង្ហាញត្រឹមត្រូវ ស្របតាមស្តង់ដានេះទេ។ ការលាតត្រដាងបន្ថែមដែលមានចែងក្នុងចំណុច (ក) ចាំបាច់ត្រូវធ្វើ នៅពេលដែលអនុលោមតាមការតម្រូវពិសេសនានាក្នុងស្តង់ដានេះនៅតែមិនគ្រប់គ្រាន់សម្រាប់ឱ្យអ្នកប្រើប្រាស់អាចយល់អំពីឥទ្ធិពលនៃប្រតិបត្តិការពិសេស ដោយឡែកនានាព្រឹត្តិការណ៍ និងស្ថានការណ៍ដទៃទៀតលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាព[8]។

## ២.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យ សម្រាប់សហគ្រាសធុនតូច និងមធ្យម

**២.៣.១ និយមន័យការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ**

ការគ្រប់គ្រងហិរញ្ញវត្ថុសំដៅទៅដល់វិធីសាស្រ្តនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់អង្គភាព និងស្ថាប័នប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពតាមរយៈការធ្វើផែនការ ការរកប្រភពធនធានការបែងចែកធនធាន ការត្រួតពិនិត្យ ការប្រើប្រាស់ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ស្ថាប័ន។ ដើម្បីឱ្យការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពបុគ្គលទទួលបន្ទុកត្រូវមានការរៀបចំផែនការថវិកា ការអនុវត្តថវិកា ការរៀបចំរបាយការណ៍ ការត្រួតពិនិត្យ ផ្ទៃក្នុង និងការធ្វើសវនកម្មខាងក្នុង និងខាងក្រៅ។

ការគ្រប់គ្រងហិរញ្ញវត្ថុគឺជាផ្នែកដ៏សំខាន់មួយនៅក្នុងអាជីវកម្ម។ ដើម្បីចាប់ផ្តើម ឬការធ្វើដំណើរការអាជីវកម្មឱ្យបានជោគជ័យក៏ត្រូវការចំណេះដឹងឱ្យបានច្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុដើម្បីសំដៅទៅលើការ

[7] វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *សវនកម្ម (Auditing) ភាគ១*. បោះពុម្ពលើកទី១១. ទំព័រទី៨. ភ្នំពេញ។

[8] និយ័តករគណនេយ្យ និងសវនកម្ម. (ឆ្នាំ២០១៥). *IFRS for SMEs*. ផ្នែកទី៣. ទំព័រទី២១. ២៩២ទំព័៥។

រៀបចំផែនការយុទ្ធសាស្ត្រការរៀបចំការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុនៅក្នុងអាជីវកម្ម ឬវិទ្យាស្ថានណាមួយ[9]។

សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមគឺដើម្បីផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុលទ្ធផលអាជីវកម្ម និងលំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចដោយអ្នក ប្រើប្រាស់ច្រើនមជ្ឈដ្ឋានរបស់របាយការណ៍ហិរញ្ញវត្ថុ ដែលមិនមានជំហរទាមទាឱ្យរបាយការណ៍ធ្វើការតម្រូវជាពិសេសដើម្បីបំពេញតម្រូវការព័ត៌មានជាក់លាក់របស់អ្នកប្រើប្រាស់ទាំងនោះ។ របាយការណ៍ហិរញ្ញវត្ថុក៏បង្ហាញនូវលទ្ធផល នៃភាពជាអ្នកគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើធនធានដែលគេបានផ្តល់ការទុកចិត្ត។

ព័ត៌មានដែលផ្តល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបង្ហាញតាមរបៀប ដែលអាចយល់បានសម្រាប់អ្នកប្រើប្រាស់ដែល មានចំណេះដឹងសមរម្យខាងសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច គណនេយ្យ ដែលមានឆន្ទៈសិក្សាអំពីព័ត៌មាននោះដោយការព្យាយាម។ ប៉ុន្តែសេចក្តីត្រូវការនូវភាពអាចយល់បាន មិនអនុញ្ញាតឱ្យព័ត៌មានដែលពាក់ព័ន្ធ ត្រូវបានខកខានមិនបានដាក់បញ្ចូលដោយសារតែប្រហែលជាពិបាកយល់ពេកសម្រាប់អ្នកប្រើប្រាស់មួយចំនួន[10]។

គឺជាតួអង្គដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ការផ្តល់ឱកាសឱ្យសហគ្រាសធុនតូច និងមធ្យមចូលរួមយ៉ាងសកម្មក្នុងបដិវត្តន៍ឧស្សាហកម្មទី៤បច្ចេកវិទ្យាឌីជីថល និងជួយជម្រុញដល់កំណើនសេដ្ឋកិច្ចតាមរយៈការបង្កើតការងារថ្មីៗ កាត់បន្ថយភាពក្រីក្រកាត់បន្ថយវិសមភាពសង្គម និងឈានដល់គោលដៅនៃអភិវឌ្ឍប្រកបដោយស្ថិរភាព។ទោះបីយ៉ាងណាក៏ដោយការជម្រុញ និងផ្តល់ឱកាសដល់សហគ្រាសធុនតូច និងមធ្យមក្នុងការចូលរួមប្រកបដោយសក្តានុពល និងទទួលបានលទ្ធផលពីសាកលភាវូបនីយកម្មបច្ចេកវិទ្យាឌីជីថលនិងសេដ្ឋកិច្ចឌីជីថល គឺអាស្រ័យលើក្របខណ្ឌគោលនយោបាយ និងការប្រកួតប្រជែងមួយមានតម្លាភាពនិងប្រសិទ្ធភាពផងដែរ។ សហគ្រាសធុនតូច និងមធ្យមជាច្រើនទទួលបរាជ័យ លើទីផ្សារដោយសារបញ្ហាផ្ទៃក្នុងផ្ទាល់ខ្លួនផងនិងរបាំងគោលនយោបាយ និងបរិយាកាសប្រកួតប្រជែងពីខាងក្រៅផង[11]។

**២.៣.២ ប្រវត្តិនៃការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ**

ការគ្រប់គ្រងហិរញ្ញវត្ថុអាចត្រូវកំណត់បានថា ការរៀបចំផែនការ ការរកប្រភព ការបែងចែក ការត្រួតពិនិត្យ ការប្រើប្រាស់ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ ស្ថាប័នដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាព និងប្រសិទ្ធផល ជាអតិបរមានៃលទ្ធផលប្រតិបត្តិការ។ កត្តាចូលរួមក្នុងការ សម្រេចក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពមានដូចជាការរៀបចំផែនការថវិកា ការអនុវត្តថវិកា ការរៀបចំរបាយការណ៍គណនេយ្យស្តង់ដា ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្មផ្ទៃក្នុង និងខាងក្រៅជាដើម[12]។

**១.សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ**

[9] អង្គភាពសវនកម្មផ្ទៃក្នុង. (2024). *ការគ្រប់គ្រងហិរញ្ញវត្ថុ*. Retrieved March, 03 2025 from https://iauoffsa.gov.kh/wp-content/uploads/2024/

[10] និយ័តករគណនេយ្យ និងសវនកម្ម (2015). *ត្រង់ផ្នែកទី២ទំព័រទី៩*. Retrieved March, 03 2025 from https://www.acar.gov.kh/

[11] ធនាគាជាតិនៃកម្ពុជា. (ឆ្នាំ២០២១). *រៀបចំដោយ សោសុន្ទរ៍ ជារី*. ទំព័រទី៧. Retrieved March, 03 2025 from https://www.nbc.gov.kh/

[12] អង្គភាពសាវនករផ្ទៃ. រៀបចំដោយលោក ឡាំ ស៊ីនឿន. (ខែមេសា ឆ្នាំ២០២៤). *IFRS for SMEs*. Retrieved March, 05 2025 from https://search.app/vzbQ5daGg2BNYWKfA

ដើម្បីសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងគោលបំណងរបស់ស្ថាប័នអ្នកគ្រប់គ្រងហិរញ្ញវត្ថុត្រូវ ប្រើប្រាស់ព័ត៌មានដែលប្រមូលបានអំពីកំណត់ត្រាហិរញ្ញវត្ថុដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវក្នុងការ បែងចែកធនធានហិរញ្ញវត្ថុ។ សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុមានដូចខាងក្រោម៖

ក. ការពង្រឹងជំនាញក្នុងការសម្រេចចិត្តគឺមានសារៈសំខាន់ណាស់សម្រាប់ការសម្រេចចិត្តក្នុងផ្នែកហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។ ដោយការរក្សាបាននូវកំណត់ត្រាដែលត្រឹមត្រូវ អ្នកគ្រប់គ្រងហិរញ្ញវត្ថុអាចកំណត់អត្តសញ្ញាណនិន្នាការនិងគម្រូដែលអាចជួយពួកគេកំណត់ឱកាស ឬហានិភ័យដែលទាក់ទងទៅនឹងស្ថាប័ន។

ខ. ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អអាចជួយដល់ស្ថាប័នក្នុងការសន្សំសំចៃថវិកាលើឧបករណ៍ប្រើប្រាស់ និងចំណាយផ្សេងៗទៀត។ ស្ថាប័នដែលមានការតាមដានការចំណាយ និងកែតម្រូវការចំណាយរបស់ខ្លួនតាមការចាំបាច់ទំនងជាមានការសន្សំសំចៃប្រកបដោយប្រសិទ្ធិភាព។

គ. ពង្រឹងការវិនិយោគឱ្យមានភាពល្អប្រសើរឡើង ដែលអ្នកគ្រប់គ្រងហិរញ្ញវត្ថុប្រើប្រាស់យុទ្ធសាស្ត្រវិនិយោគជាច្រើនដើម្បីជួយឱ្យស្ថាប័នសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរយៈពេលវែង។ ការវិនិយោគដែលបានគ្រោងទុកត្រឹមត្រូវនឹងអាចផ្តល់នូវស្ថិរភាព និងកំណើនក្នុងរយៈពេលវែងដល់ស្ថាប័ន។

ឃ. ការការពារពីវិបត្តិហិរញ្ញវត្ថុស្ថាប័នដែលគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនមិនបានល្អអាចនាំឱ្យកើតមានផលវិបាកធ្ងន់ធ្ងរដូចជាការរឹបអូសទ្រព្យសម្បត្តិ ឬការក្ស័យធនជាដើម។ ជាទូទៅតាមស្ថាប័នដែលគ្រប់គ្រងហិរញ្ញវត្ថុបានល្អ នៅតែអាចដំណើរការបានល្អក្នុងគ្រាសេដ្ឋកិច្ចលំបាកផងដែរ។

ង. ជាមាគ៌ាសម្រាប់ក្រុមប្រឹក្សាភិបាលដើម្បីបញ្ជាក់ឡើងវិញ ឬបង្កើតគោលនយោបាយហិរញ្ញវត្ថុឡើង វិញដោយផ្អែកលើគោលនយោបាយស្តង់ដាគណនេយ្យ។

ច. អាចឱ្យអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ដោយផ្អែកលើការផ្តល់របាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា អ្នកគ្រប់គ្រងអាចធ្វើសកម្មភាពតាមគម្រោងផែនការ ឬស្វែងរកមូលនិធិបន្ថែមប្រសិនបើ ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ ក៏អាចវាស់វែងអំពីសមត្ថភាពរបស់ស្ថាប័នដើម្បីពង្រីកកម្មវិធីរបស់ស្ថាប័នផងដែរ។

ឆ. ផ្តល់ឱ្យស្ថាប័ននូវអត្ថប្រយោជន៍ដែលចាំបាច់លើការគ្រប់គ្រងធនធានដែលខ្វះខាត ពីព្រោះម្ចាស់ជំនួយយកចិត្តទុកដាក់ជាខ្លាំងទៅលើថវិកាជំនួយដែលប្រើប្រាស់ដោយស្ថាប័ន ហេតុនេះស្ថាប័នដែលមានជំហរហិរញ្ញវត្ថុល្អត្រូវបានចាត់ទុកថាមានប្រៀបលើស្ថាប័នដែលមានការគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិត។

ជ. បង្កើត និងពង្រឹងភាពជឿជាក់របស់អ្នកពាក់ព័ន្ធមកលើស្ថាប័ន។

ឈ.ធានានូវការអនុវត្តគម្រោងដូចដែលបានគ្រោងទុក ដោយមានការបែងចែកថវិកាបានត្រឹមត្រូវ គ្មានគម្រោងណាមួយត្រូវបោះបង់ដោយសារតែស្ថាប័នខ្វះមូលនិធិនៅចុងឆ្នាំនោះទេ។

ញ.បង្កើតឱ្យមានលំហូរសាច់ប្រាក់វិជ្ជមានក្នុងស្ថាប័ន។

ដ. ការពារទ្រព្យសម្បត្តិរបស់ស្ថាប័ន។

ឆ. ផ្តល់ឱ្យស្ថាប័ននូវអត្ថប្រយោជន៍ដែលចាំបាច់លើការគ្រប់គ្រងធនធានដែលខ្វះខាត ពីព្រោះម្ចាស់ជំនួយយកចិត្តទុកដាក់ជាខ្លាំងទៅលើថវិកាជំនួយដែលប្រើប្រាស់ដោយស្ថាប័ន ហេតុនេះស្ថាប័នដែលមានជំហរហិរញ្ញវត្ថុល្អត្រូវបានចាត់ទុកថាមានប្រៀបលើស្ថាប័នដែលមានការគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិត។

ជ. បង្កើត និងពង្រឹងភាពជឿជាក់របស់អ្នកពាក់ព័ន្ធមកលើស្ថាប័ន។

ឈ.ធានានូវការអនុវត្តគម្រោងដូចដែលបានគ្រោងទុកដោយមានការបែងចែកថវិកាបានត្រឹមត្រូវគ្មានគម្រោងណាមួយត្រូវបោះបង់ដោយសារតែស្ថាប័នខ្វះមូលនិធិនៅចុងឆ្នាំនោះទេ។

ញ. បង្កើតឱ្យមានលំហូរសាច់ប្រាក់វិជ្ជមានក្នុងស្ថាប័ន។

ដ. ការពារទ្រព្យសម្បត្តិរបស់ស្ថាប័ន។

ឋ. ជួយស្ថាប័នក្នុងការរៀបចំផែនការដើម្បីបង្កើនមូលនិធិដោយខ្លួនឯងដែលធ្វើឱ្យមាននិរន្តរភាពក្នុងស្ថាប័ន[13]។

**២.៣.៣ ទ្រឹស្តីនៃការគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ**

ទ្រឹស្តីការគ្រប់គ្រងហិរញ្ញវត្ថុអាចត្រូវបានកំណត់ថាជាការរៀបចំផែនការ ការរកប្រភព ការបែងចែក ការត្រួតពិនិត្យ ការប្រើប្រាស់ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ស្ថាប័នដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធិភាព និងប្រសិទ្ធផលជាអតិបរមានៃលទ្ធផលប្រត្តិបត្តិការ។ កត្តាចូលរួមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាពមានដូចជាការរៀបចំផែនការថវិកា ការអនុវត្តថវិកាការរៀបចំរបាយការណ៍គណនេយ្យស្តង់ដាការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្មខាងក្នុងនិងខាងក្រៅជាដើម។ បន្ថែមពីនេះអ្នកគ្រប់គ្រង ហិរញ្ញវត្ថុត្រូវពិចារណាពីស្ថានភាពហិរញ្ញវត្ថុទូទៅរបស់ស្ថាប័នរួមទាំងលំហូរសាច់ប្រាក់ការវិនិយោគ និងធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រអំពីកន្លែងដែលត្រូវបែងចែកធនធានដើម្បីបំពេញគោលដៅរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

**១.តួអង្គសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ**

តួអង្គសំខាន់ៗ និងការទទួលខុសត្រូវចម្បងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងស្ថាប័ន រួមមានដូចខាងក្រោម៖

ក. ក្រុមប្រឹក្សាភិបាល៖ ធានានូវតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ប្រភពធនធានរបស់ស្ថាប័នដោយផ្អែកលើគុណតម្លៃស្ថាប័ន ទស្សនៈវិស័យ និងបេសកកម្មដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ន។

ខ. ថ្នាក់គ្រប់គ្រង៖ ដើរតួយ៉ាងសំខាន់ក្នុងការធានាបានថាធនធានរបស់ស្ថាប័នត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាព ប្រសិទ្ធផល និងភាពសន្សំសំចៃដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ន។

គ. អ្នកគ្រប់គ្រងកម្មវិធី៖ ធានាបាននូវតម្លាភាពហិរញ្ញវត្ថុនៃកម្មវិធី ដែលក្នុងនោះការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងកម្មវិធីគឺដើម្បីរារាំងការក្លែងបន្លំធំៗ ដោយដាក់នៅមូលដ្ឋានប្រព័ន្ធត្រួតពិនិត្យដ៏ល្អ និងធ្វើការពិនិត្យឡើងវិញដោយខ្លួនឯង។ គន្លឹះសំខាន់គឺធ្វើការវិនិច្ឆ័យថាតើមានហានិភ័យពិតប្រាកដអ្វីខ្លះកើតឡើង បន្ទាប់មកត្រូវរកវិធីសាស្ត្រដើម្បីលុបបំបាត់ និងកាត់បន្ថយហានិភ័យទាំងនោះ។ លើសពីនេះទៅទៀតអ្នកគ្រប់គ្រងកម្មវិធីត្រូវតែទទួលខុសត្រូវនូវក្នុងការធានាថាគម្រោងនៃ ថវិកាត្រូវបានបង្កើតឡើងដោយផ្អែកលើផែនការសកម្មភាពត្រឹមត្រូវ និងត្រូវបានតាមដានលើការរីកចម្រើន និងការប្រើប្រាស់មូលនិធិដោយផ្អែកលើថវិកាដែលបានអនុម័ត។

[13] អង្គភាពសវនកម្មផ្ទៃក្នុង. (ឆ្នាំ២០២៤). *សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ*. ត្រង់ទំព័រទី៥ និងទី៦. Retrieved March, 03 2025 from https://search.app/tQbYHLjXZ52DHoK47

ឃ. អ្នកគ្រប់គ្រងហិរញ្ញវត្ថុ៖ ទទួលខុសត្រូវលើប្រតិបត្តិការទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័ន ធានាបានថាប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ត្រូវគោរពតាមគោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុរបស់ស្ថាប័ន និងត្រូវបានគាំទ្រដោយឯកសារយោងគ្រប់គ្រាន់ត្រឹមត្រូវ។ ក្រៅពីនេះត្រូវធានាបានថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំត្រឹមត្រូវនិងទាន់ពេលវេលា។

ង. គណនេយ្យករ៖ ទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្ត និងទាន់ពេលវេលាដែលអនុលោមតាមគោលការណ៍គណនេយ្យ ដើម្បីជួយដល់អ្នកគ្រប់គ្រងក្នុងការសម្រេចចិត្តលើផ្នែកហិរញ្ញវត្ថុបានត្រឹមត្រូវ។

ច. បេឡាករ៖ ទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិ និងឯកសារដែលពាក់ព័ន្ធផ្សេងៗ ដូចជាសាច់ប្រាក់ មូលប្បទានបត្រសៀវភៅធនាគារ និងសោរទូដែក ឬលេខកូដសុវត្ថិភាពរបស់ទូដែក។ លើសពីនេះទៀតបេឡាករក៏ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍សាច់ប្រាក់ប្រចាំថ្ងៃដើម្បីធានាបានថាការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុចូលក្នុងប្រព័ន្ធគណនេយ្យមានភាពត្រឹមត្រូវ និងទាន់ពេលវេលា[14]។

[14] អង្គភាពសាវនករផ្ទៃក្នុង. (ឆ្នាំ២០២៤). *តួអង្គសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ* :https://search.app/tQbYHLjXZ52DHoK47 ទំព័រទី៦ និងទី៧

# ជំពូកទី៣
# សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

## ៣.១ ស្ថានភាពទូទៅរបស់និយ័តករគណនេយ្យ និងសវនកម្ម

### ៣.១.១ ប្រវត្តិនិយ័តករគណនេយ្យ និងសវនកម្ម

ប្រវត្តិសង្ខេបនៃក្រុមប្រឹក្សាជាតិគណនេយ្យ (National Accounting Council នៃកម្ពុជា) គឺជាស្ថាប័នរដ្ឋមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ដោយអនុក្រឹត្យរដ្ឋាភិបាលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយអភិវឌ្ឍគណនេយ្យជាតិក្នុងវិស័យសាធារណៈនិងឯកជន។

- ទិសដៅឆ្នាំ ១៩៩៩–២០០៣
- ២១ មេសា ១៩៩៩: មានកំណើត គណៈកម្មការស្រាវជ្រាវស្តង់ដាគណនេយ្យអន្តរជាតិដែលមាន ៧ នាក់ដឹកនាំដោយ H.E. Ngy Tayi
- ០៨ កក្កដា ២០០២: ដាក់បង្កើតជាផ្លូវច្បាប់ NAC តាមលក្ខខណ្ឌនៃច្បាប់អំពីគណនេយ្យឯកជន និងវិស័យសេដ្ឋកិច្ច
- ០៣ មីនា ២០០៣: ស្តីពីរចនាសម្ព័ន្ធ និងមុខងារ NAC។
- ខួបព្រឹត្តិការណ៍សំខាន់
- ថ្ងៃ១៤ មករា ២០១៦ NAC បង្កើតតាមច្បាប់ "Law on Accounting and Auditing"
- ថ្ងៃ១ មករា ២០១០–២០១២ អនុម័ត CIFRS និង IFRS នៅកម្ពុជា
- គោលដៅនិងភារៈកិច្ចមួយចំនួន
- ការបង្កើត និងអភិវឌ្ឍស្តង់ដា CAS (Cambodian Accounting Standards) ដែលមានប្រើប្រាស់សម្រាប់សហគ្រាសធំ និងមធ្យមចាប់ពីឆ្នាំ ២០០៥
- សហស្ថាន KICPAA (Kampuchea Institute of Certified Public Accountants and Auditors) ដែលបានបង្កើតក្នុងឆ្នាំ២០០២ ដើម្បីគ្រប់គ្រងវិស័យវិជ្ជាជីវៈCPA/Auditor និងដាក់ក្រុមប្រតិបត្តិការ
- គណនេយ្យជាតិបានអនុម័ត IFRS និង IFRS for SMEs ពី០៨ មករា ២០០៩ពិនិត្យ និងអនុវត្តមុនឆ្នាំ ២០២០ NAC ផ្តល់ការអប់រំពីស្តង់ដា និងបណ្តុះបណ្តាលជាច្រើន ប៉ុន្តែមិនបានបង្ខំឱ្យដាក់របាយការណ៍ទៅ NAC ឱ្យបញ្ជាក់ជាផ្លូវការទេ
- ឆ្នាំ ២០២០ NAC ចាប់ផ្តើមអនុវត្តរៀបចំហើយបង្ខំឱ្យឯកត្តភាគីដាក់របាយការណ៍ហិរញ្ញវត្ថុ
- ចាប់ពី ខែមករា ២០២១ អាជ្ញាកណ្តាល "Accounting and Auditing Regulator" ត្រូវបានបង្កើតតំណាងញឹកញយក្រុមប្រឹក្សាជាតិ NAC ហើយទទួលភារកិច្ចមួយចំនួនពី NAC
- ACAR មានភារកិច្ចសំខាន់ៗ៖ ចេញអាជ្ញាប័ណ្ណ ត្រួតពិនិត្យគុណភាពសវនកម្ម ចេញក្រមសីលធម៌ និងត្រួតពិនិត្យវិវាទវិជ្ជាជីវៈ។
- មករា ២០២១ NAC ផ្លាស់ប្តូរទៅជា Accounting and Auditing Regulator ក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងចេញស្តង់ដាគណនេយ្យនៅ

កម្ពុជា ក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ទាប់ពីការបញ្ចូលស្តង់ដាអន្តរជាតិ និងជំហានធំៗក្នុងការផ្លាស់ប្តូរទៅ ACAR នៅឆ្នាំ២០២១NACបានប្តូរតួនាទីទៅជាអាជ្ញាធរត្រួតពិនិត្យស្វ័យប្រវត្តិ វិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែម្តង។




**៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់គណនេយ្យ និងសវនកម្ម**

**ក.ចក្ខុវិស័យ**

និយ័តករគណនេយ្យ និងសវនកម្មនឹងក្លាយជាស្ថាប័ននិយ័តករដែលមានសមត្ថភាពនិងគុណតម្លៃវិជ្ជាជីវៈព្រមទាំងមានកិច្ចដំណើរការប្រកបដោយនិរន្តភាពនិងគណនេយ្យភាព ដោយទទួលបាននូវការទុកចិត្តពីរាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មដើម្បីទ្រទ្រង់និងគាំពារការអភិវឌ្ឍលើគ្រប់វិស័យ ពិសេសវិស័យហិរញ្ញវត្ថុ សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។

**ខ.បេសកកម្ម**

និយ័តករគណនេយ្យ និងសវនកម្មបំពេញមុខងារជាសេនាធិការឱ្យ អ.ស.ហ. ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍវិស័យវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជាតាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិវិធាន និងស្តង់ដាព្រមទាំងជំរុញការអនុវត្តច្បាប់ស្តង់ដាគណនេយ្យ និងសវនកម្មនៅកម្ពុជា។

**៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់គណនេយ្យនិងសវនកម្ម**

ក. រចនាសម្ព័ន្ធគ្រប់គ្រង




ខ. តួនាទីគណគ្រប់គ្រង

**នាយកដ្ឋាននៃនិយ័តករគណនេយ្យ និងសវនកម្ម**

នាយកដ្ឋានកិច្ចការទូទៅជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

-សម្របសម្រួល និងបូកសរុបផែនការសកម្មភាពរួម របស់ ន.គ.ស.

-រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការទូទៅ

-រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់ ន.គ.ស.

-គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់ ន.គ.ស.

-សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់ ន.គ.ស.

-គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលត្រូវបានបែងចែកឱ្យនៅក្រោម ន.គ.ស. និងរៀបចំបញ្ជីសារពើភ័ណ្ឌ

-រៀបចំដាក់ឱ្យដំណើរការ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងការផ្សព្វផ្សាយរបស់ ន.គ.ស.

-ទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ និងវិស័យឯកជន

-ផ្សព្វផ្សាយជាសាធារណៈពីកិច្ចដំណើរការនិងវឌ្ឍនភាពរបស់ ន.គ.ស.

-អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អង្គនាយកនៃ ន.គ.ស.

នាយកដ្ឋានបច្ចេកទេសជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

-រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានបច្ចេកទេស

-សិក្សាស្រាវជ្រាវ និងរៀបចំស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជជីវៈ និងស្តង់ដាពាក់ព័ន្ធ

-ពន្យល់ និងបកស្រាយលើទិដ្ឋភាពបច្ចេកទេសនៃស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជជីវៈ និងស្តង់ដាពាក់ព័ន្ធ

-ពិនិត្យឡើងវិញលើការអនុវត្តស្តង់ដា និងកំណត់បញ្ហាប្រឈម ទាំងទិន្នភាពបច្ចេកទេទិដ្ឋភាពបទប្បញ្ញត្តិ ព្រមទាំងស្នើឡើងនូវដំណោះស្រាយ

-សហការនិងចូលរួមជាមួយស្ថាប័នតំបន់ និងអន្តរជាតិ ក្នុងការរៀបចំធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍស្តង់ដាគណនេយ្យ ស្តង់ដា សវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ

- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ ន.គ.ស. ។

- នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មជាសេនាធិការឱ្យ ន.គ.ស. លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

  - រៀបចំអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
  - ពិនិត្យនិងផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
  - បានត្រួតពិនិត្យ និងផ្តល់យោបល់លើវិធានការចំពោះអំពើល្មើសទៅនឹងបទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
  - រៀបចំ និងធ្វើបច្ចុប្បន្នភាពប្បញ្ញត្តិចាំបាច់នានា ទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
  - ត្រួតពិនិត្យគុណភាពសេវាគណនេយ្យ និងសវនកម្ម
  - រៀបចំ និងគ្រប់គ្រងទិន្នន័យក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម
  - រៀបចំ ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
  - រៀបចំដាក់ឱ្យដំណើរការ និងគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
  - ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងទៅនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន
  - អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អគ្គនាយក ន.គ.ស. ។

- នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាពជាសេនាធិការឱ្យ ន.គ.ស.លើតួនាទី និងភារកិច្ចដូចខាងក្រោម៖

  - រៀបចំ និងអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព
  - រៀបចំ និងធ្វើបច្ចុប្បន្នភាពប្បញ្ញត្តិចាំបាច់នានា
  - ពិនិត្យ និងផ្តល់យោបល់លើវិធានការពង្រឹងការអនុវត្តច្បាប់
  - រៀបចំ និងគ្រប់គ្រងទិន្នន័យអំពីសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
  - ត្រួតពិនិត្យអនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
  - គ្រប់គ្រង ត្រួតពិនិត្យទាំងលើឯកសារ និងទៅដល់ទីកន្លែងផ្ទាល់ និងវាយតម្លៃលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាព មិនស្វែងរកប្រាក់ចំណេញ

- ចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទាន
- រៀបចំការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយច្បាប់ បទប្បញ្ញត្តិ និងស្តង់ដាពាក់ព័ន្ធ
- អនុវត្តការងារផ្សេងទៀត តាមការណែនាំរបស់អង្គនាយកនៃ ន.គ.ស. ។

## ៣.២ គោលបំណងនៃការរៀបចំស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

### ៣.២.១ ដើម្បីសម្រួលការចងក្រង និងរៀបចំរបាយការណ៍

ការរៀបចំសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺនិយាយអំពីគោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យមនិងគុណភាពដែលធ្វើឱ្យព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានសារៈប្រយោជន៍ក្នុងការប្រើប្រាស់។ គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូច និងមធ្យមគឺដើម្បីផ្តល់ព័ត៌មានពីស្ថានភាពហិរញ្ញវត្ថុលទ្ធផលហិរញ្ញវត្ថុ លំហូរសាច់ប្រាក់របស់សហគ្រាសដែលមានសារៈប្រយោជន៍ដល់ការធ្វើសេចក្តីសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដូចជាម្ចាស់សហគ្រាសជាដើម។

របាយការណ៍ហិរញ្ញវត្ថុ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ធនាគារ និងក្នុងការសម្រេចចិត្តឥណទាននិងផ្តល់ទុនវិនិយោគដល់ក្រុមហ៊ុនអាជីវកម្ម។ លើសពីនេះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវតាមស្តង់ដាបច្ចេកទេស អាចផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ដំណើរការនៃការគ្រប់គ្រងអាជីវកម្មដូចជា ជំនួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការគ្រប់គ្រងបំណុល និងការគ្រប់គ្រងទុនបង្វិលជាដើម។

❖ ទម្រង់និងគម្រូស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម (SMEs) ត្រូវបានរៀបចំឡើងដើម្បីឱ្យអាជីវកម្មអាចសម្របខ្លួនឱ្យសមស្របទៅនឹងសមត្ថភាព និងធនធានរបស់ខ្លួន។ ស្ថាប័នដូចជា NCAC) ឬIFRS for SMEs បានផ្តល់នូវស្តង់ដាដែល SMEs អាចអនុវត្តបាន។

❖ **ប្រភេទរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុមាន៥ប្រភេទដូចជា៖

- របាយការណ៍តុល្យការ ( Balance Sheet or Statement of Financial Position)
- របាយការណ៍លទ្ធផល (Income Statement or Profit and loss statement)
- របាយការណ៍បម្រែបម្រួលមូលធន ( Statement of Stockholders’ Equity Change)
- របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flows)
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ(Note to Financial Statement)

**១. របាយការណ៍តុល្យការ៖** ដែលបង្ហាញពីតុល្យការទ្រព្យសកម្ម និងដើមទុននៅក្នុងកំឡុងពេលជាក់លាក់មួយបង្ហាញស្ថានភាពហិរញ្ញវត្ថុរបស់អាជីវកម្មទៅតាមកាលបរិច្ឆេទជាក់លាក់ណាមួយ ដោយបញ្ចូលទិន្នន័យនៃទ្រព្យ និងបំណុលរបស់អាជីវកម្ម។ ក្រៅពីនោះវាក៏បង្ហាញពីតារាងចរន្តសាច់ប្រាក់ គណនីទទួល និងទូទាត់ប្រាក់ និងស្ថានភាពជាក់ស្តែងនៃអាជីវកម្ម ដែលជួយឱ្យអ្នកប្រើប្រាស់ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងរៀបចំពេលវេលា។ ក្នុងករណីអ្នកស្នើសុំកម្ចីរបាយការណ៍នេះក៏អាចជាឯកសារមួយជួយឱ្យអ្នកផ្តល់កម្ចីអាចត្រួតពិនិត្យ និងវិភាគថាអ្នកមានសមត្ថភាពស្នើរបានប៉ុណ្ណាដែរ។

❖ **តារាងតុល្យភាព (Balance sheet or Statement of Financial )**

- ទ្រព្យសកម្ម ( Assets)

- មូលធនម្ចាស់ (Equity )
- បំណុល ( Liabilities)

**២. របាយការណ៍ចំណេញខាត(Income Statement)៖** ដែលបង្ហាញពីចំណូល និងចំណាយ ព្រមទាំងលទ្ធផលចំណេញខាតសម្រាប់ប្រតិបត្តិការអាជីវកម្មក្នុងការិយបរិច្ឆេទជាក់លាក់ណាមួយ។

❖ **បញ្ជីប្រាក់ចំណូល ( Statement of Comprehensive Income)**

- ចំណូលប្រតិបត្តិការ (Revenue)
- ចំណាយដកថ្លៃដើម (Expenses)
- ប្រាក់ចំណេញសុទ្ធ (Net Profit or Loss )

**៣. របាយការណ៍លំហូរសាច់ប្រាក់( Statement of Cash Flows)៖** ដែលបង្ហាញពីលំហូសាច់ប្រាក់ចេញ និងលំហូសាច់ប្រាក់ចូល ពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន របស់អាជីវកម្មនៅក្នុងការិយបរិច្ឆេទជាក់លាក់ណាមួយ។

❖ **របាយការណ៍លំហូរសាច់ប្រាក់(Statement of Cash Flows)**

- លំហូរចេញចូលពីប្រតិបត្តិកាដែលទទួលបានពីការលក់ (Operating activities)
- ពាណិជ្ជកម្មទ្រព្យសកម្ម (Investing activities)
- ផ្នែកហិរញ្ញវត្ថុ (Financing activities)

**៤. របាយការណ៍បម្រែបម្រួលមូលធន(Statement of Stockholders Equity Change)៖** ដែលបង្ហាញពីការប្រែប្រួលសមតុល្យទុនរបស់ម្ចាស់អាជីវកម្ម។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គឺមានដំណើរការនៃការប្រមូលផ្តុំព័ត៌មានគណនេយ្យទៅក្នុងទម្រង់ស្តង់ដាមួយ ដើម្បីសង្ខេបទៅជារបាយការណ៍។ ក្នុងនោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមមានជំហានសំខាន់ៗដូចជា៖

❖ **របាយការណ៍ផ្លាស់ប្តូរមូលធនម្ចាស់ (Statement of Changes in Equity)**

- បង្ហាញពីការកើនឡើង និងការថយចុះនៃមូលធនម្ចាស់ក្នុងរយៈពេលណាមួយ
- បង្ហាញព័ត៌មានលម្អិតបន្ថែមដែលពាក់ព័ន្ធនឹងទិន្នន័យក្នុងរបាយការណ៍
- ពន្យល់អំពីគោលការណ៍គណនេយ្យ ចំណេញសុទ្ធ ការបន្ថែមទុន
- ព័ត៌មានបន្ថែមអំពីធាតុនៅក្នុងរបាយការណ៍

ដើម្បីបញ្ជាក់បន្ថែមសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលនៅក្នុងប្រទេសកម្ពុជាក៏អាចប្រើប្រភេទ Financial Reporting Framework ដូចជាCIFRS for SMEs( Cambodian International Financial Reporting Standard for SMEs ) ដែលបានកែសម្រួលពី IFRS for SMEs ដោយស្ថាប័នជាតិគណនេយ្យ។

ក.គម្រូនៃរបាយការណ៍លទ្ធផល(Income Statement)

| Company Name<br>Income Statement<br>For the year ended December 20X1 & 20XX | | |
|---|---|---|
| **Account Tittle** | **20X1** | **20XX** |
| **Period Ending** | | |
| Total Revenue | XXXXX | XXXXX |
| Cost of Revenue | XXXXX | XXXXX |
| **Gross Profit** | XXXXX | XXXXX |
| **Operation Expense** | | |
| Research and Development | XXXXX | XXXXX |
| Sales, General and Admin. | XXXXX | XXXXX |
| Non-Recurring Items | XXXXX | XXXXX |
| Other Operating Items | XXXXX | XXXXX |
| **Operating Income** | XXXXX | XXXXX |
| Add income/expense items | XXXXX | XXXXX |
| Earnings Before Interest and Tax | XXXXX | XXXXX |
| Interest Expense | XXXXX | XXXXX |
| Earnings Before Tax | XXXXX | XXXXX |
| Income Tax: | XXXXX | XXXXX |
| Minority Interest | XXXXX | XXXXX |
| EquityEarnings/LossUnconsolidated Subsidiary | XXXXX | XXXXX |
| Net Income-Cont. Operations | XXXXX | XXXXX |
| **Net Income** | XXXXX | XXXXX |
| NetIncomeApplicabletoCommon Shareholders | XXXXX | XXXXX |

សមាសភាពសំខាន់ៗនៃរបាយការណ៍លទ្ធផលមាន៖

- ចំណូល (Revenue) គឺជាលំហូរចូលនៃសាច់ប្រាក់ ឬជាតុផ្សេងៗ ដែលធ្វើឱ្យទ្រព្យរបស់អង្គភាពមានការកើនឡើង ឬការសងបំណុលក្នុងកំឡុងពេលផ្តល់សេវាកម្ម ឬផលិតផល របស់ក្រុមហ៊ុន។
- ចំណាយ(Expenses) គឺជាលំហូរចេញនៃសាច់ប្រាក់ ក្នុងសកម្មភាពដំណើរការរបស់អង្គភាពពាក់ព័ន្ធនឹងការទូទាត់ទ្រព្យសកម្ម និងបំណុលកំឡុងពេលផ្តល់សេវាកម្ម ឬផលិតផលរបស់ក្រុមហ៊ុន។
- ចំណេញដុល (Gain) គឺជាការកើនឡើងនូវប្រាក់ចំណេញសុទ្ធដែលទទួលបានពីប្រតិបត្តិការចរន្តក្រៅពីប្រាក់ចំណូលដោយមិនផ្សារភ្ជាប់ជាមួយការវិនិយោគ និងការដកសាច់ប្រាក់ ។
- ការខាតបង់ (Loss) គឺជាថយចុះនូវប្រាក់ចំណូលសុទ្ធ ដែលនៅក្រៅប្រតិបត្តិការធម្មតារបស់អាជីវកម្ម។

ខ. គម្រូនៃរបាយការណ៍តុល្យការ(Balance Sheet)

| Company Name<br>Statement of Financial Position<br>For the year ended December 20X1 & 20XX | | |
|---|---|---|
| **Account Tittle** | **20X1** | **20XX** |
| **Period Ending** | | |
| **Assets:** | | |
| **Non-Current Assets** | XXXXX | XXXXX |
| Long -Term Investment | XXXXX | XXXXX |
| Fixed Assets | XXXXX | XXXXX |
| Good will | XXXXX | XXXXX |
| Intangible Assets | XXXXX | XXXXX |
| **Total Non-Current Assets** | XXXXX | XXXXX |

| | | |
|---|---|---|
| **Current Assets** | XXXXX | XXXXX |
| Cash and Cash Equivalents | XXXXX | XXXXX |
| Short-Term Investments | XXXXX | XXXXX |
| Net Receivables | XXXXX | XXXXX |
| Inventory | XXXXX | XXXXX |
| Other current Assets | XXXXX | XXXXX |
| **Total Current Assets:** | XXXXX | XXXXX |
| **Total Assets:** | XXXXX | XXXXX |
| **Stockholder Equity:** | | |
| Common Stocks | XXXXX | XXXXX |
| Capital surplus | XXXXX | XXXXX |
| Retained Earning | XXXXX | XXXXX |
| Treasury Stock | XXXXX | XXXXX |
| Other Equity | XXXXX | XXXXX |
| **Total Stockholder Equity:** | XXXXX | XXXXX |
| **Liabilities** | | |
| Non-Current Liabilities | XXXXX | XXXXX |
| Long -Term Debt | XXXXX | XXXXX |
| Other liabilities | XXXXX | XXXXX |
| Deferred Liabilities Charges | XXXXX | XXXXX |
| Misc. Stocks | XXXXX | XXXXX |
| Minority Interest | XXXXX | XXXXX |
| **Non-Current Liabilities** | XXXXX | XXXXX |
| **Current Liabilities** | XXXXX | XXXXX |
| Account Payable | XXXXX | XXXXX |
| Short-Term Debt | XXXXX | XXXXX |
| Other Current Liabilities | XXXXX | XXXXX |
| **Total Current Liabilities** | XXXXX | XXXXX |
| **Total Stockholder Equity and Liabilities** | XXXXX | XXXXX |

- ទ្រព្យសកម្ម( Assets )គឺជាទ្រព្យទាំងឡាយណាដែលគ្រប់គ្រងដោយអង្គភាព ឬរាជរដ្ឋាភិបាល ហើយរំពឹងថាវានឹងបង្កើតអត្ថប្រយោជន៍នាពេលអនាគត
- បំណុល ( Liabilities ) គឺជាគណនីសម្រាប់ប្រើក្នុងការកត់ត្រាបំណុលរបស់ក្រុមហ៊ុនសហគ្រាសដែលវាក៏ត្រូវបានរាយការណ៍ទៅក្នុងរបាយការណ៍តុល្យការផងដែរ
- មូលធន (Equity) គឺជាដើមទុន ឬធនធានទាំងឡាយដែលរួមចំណែកដល់ផលិតកម្ម ឬការវិនិយោគសម្រាប់បង្កើត និងពង្រីកអាជីវកម្មរបស់អង្គភាព។

គ. គម្រូនៃរបាយការណ៍បម្រែបម្រួលមូលធន(Statement of Stockholders' Equity Change)

| **Company Name<br>Statement of Retain Earning<br>For the Year ended December 20X1 & 20XX** | | |
|---|---|---|
| Retained Earnings October 1 | | XXXXX |
| Add: Net Income | | XXXXX |
| Less: dividends | | |
| Cash dividends on Preferred Stock | XXXXX | |
| Cash dividends on Common Stock | XXXXXX | |
| Stock dividends | XXXXXX | |
| Retained earnings October 31 20XX | | XXXXX |

ឃ. គម្រូនៃរបាយការណ៍លំហូរសាច់ប្រាក់(Cash Flow Statement)

| Company Name<br>Statement of Cash Flow<br>For the Year ended December 20X1 & 20XX | | |
|---|---|---|
| **Account Tittle** | **20X1** | **20XX** |
| **Period Ending** | XXXXX | XXXXX |
| Net Income | | |
| **Cash Flow-Operating Activities** | | |
| Depreciation | XXXXX | XXXXX |
| Net Income Adjustments | XXXXX | ( XXXXX ) |
| **Change in Operating Activities** | | |
| Accounts Receivable | | |
| Changes in Inventories | | |
| Other Operating Activities | XXXXX | XXXXX |
| Liabilities | | |
| | XXXXX | XXXXX |
| | XXXXX | XXXXX |
| | XXXXX | XXXXX |
| **Net Cash Flow-Operating** | XXXXX | XXXXX |
| **Cash Flow-Investment Activities** | | |
| Capital Expenditures | ( XXXXX ) | ( XXXX ) |
| Investments | XXXXXX | XXXXX |
| Other Investing Activities | XXXXXX | XXXXX |
| **Net Cash Flow-Investing** | ( XXXXX ) | ( XXXXX ) |

| | | |
|---|---|---|
| **Cash Flow-Financing Activities** | | |
| Sale and Purchase of stock | XXXXXX | XXXXXX |
| Net Borrowing | ( XXXXX ) | ( XXXXX ) |
| Other Financing Activities | ( XXXXX ) | ( XXXXX ) |
| **Net Cash Flows-Financing** | ( XXXXX ) | ( XXXXX ) |
| Effect of Exchange Rate | ( XXXXX ) | ( XXXXX ) |
| **Net Cash Flow** | ( XXXXX ) | ( XXXXX ) |

**ង.** របាយការណ៍កំណត់សម្គាល់ហិរញ្ញវត្ថុ គឺជាសមាសធាតុសំខាន់មួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលជួយបង្ហាញពីព័ត៌មានលម្អិតនៃទិន្នន័យ និងលេខនានាដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

**៥.១ គោលនយោបាយគណនេយ្យសំខាន់ៗ**

1- តើសហគ្រាសរកស៊ីអ្វី? អាសយដ្ឋាននៅឯណា?

2- តើFS សម្រាប់ការិយបរិច្ឆេទពីថ្ងៃណាដល់ថ្ងៃណា?

3- តើសមាសភាពអ្នកចូលហ៊ុន?

4- តើCash ផ្សំដោយបញ្ញើនៅBankណាខ្លះ?

5- តើCash Equivalent គួបផ្សំដោយសមាសភាព Cash ណាខ្លះ?

6- តើ Account Receivable អ្នកណាជំពាក់ខ្លះ? មានធ្វើសំវិធានធនដែរឬទេ? ធ្វើតាមវិធីសាស្ត្រអ្វី?

7- តើInventory បង្ហាញជាថ្លៃដើមប្រវត្តិសាស្ត្រ ឬតម្លៃលក់ពិត? ជាប់ឆ្នាំមានធ្វើ LCM ឬទេ?

តើការគណនា ឬ ការវាយតម្លៃសន្និធិចុងគ្រាតាម Cost average, FIFO or LIFO?

8- PP&E (រោងចក្រ និងបរិក្ខារអចលនទ្រព្យ)

- តើកត់ត្រានៅតម្លៃ cost of purchase or purchase price or historical cost?
- តើរំលស់ប្រើតាមវិធីអ្វី? Straight-Line Method, DDBM or DBM?
- តើការប៉ាន់ស្មានចំនួនឆ្នាំរំលស់ ឈរទៅលើការស្មានព្រាវៗ ឬ ផ្អែកលើ Future Economy Benefit របស់ PP&E?
- តើមានធ្វើសំវិធានធនលើ PP&E (Impairment Loss) ឬទេ?

**3.Inventory**

- កត់ត្រាជាតម្លៃ Historical cost
- គណនាស្តុកចុងតាមវិធីសាស្រ្ត FIFO
- Report ជា LCM

**៤. PP&E**

- កត់ត្រាជាតម្លៃ Historical cost
- ការប៉ាន់ស្មានអាយុកាលរំលស់ផ្អែកតាម Future economic benefit of PP&E
- រំលស់គណនាតាមវិធីសាស្រ្តរំលស់ថេរ (Straight-Line Method)

**៥.២ Additional Information Support on the Finance Statement**

- Comply with US GAAP or Other Generally Accepted
- Accrual Basis System
- Going Concerns
- Consistency (ភាពមិនប្រែប្រួល)

**៥.៣ Supplemantary Information**

- Financail Statement by Management
- Value Added Staement
- Environmental Report

## ៥. គន្លឹះក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមានដូចជា៖

❖ ជំហានទី១

ផ្ទៀងផ្ទាត់វិក្កយបត្រអ្នកផ្គត់ផ្គង់៖ ប្រៀបធៀបកំណត់ហេតុទទួលទៅនិងគណនីដែលត្រូវបង់ ដើម្បីធានាថាវិក្កយបត្រអ្នកផ្គត់ផ្គង់ទាំងអស់ត្រូវបានទទួលកត់ត្រា។ ត្រូវធ្វើការកត់ត្រាជាចំណាយបង្គរសម្រាប់ចំណាយដែលបានកើតឡើងហើយ តែមិនទាន់ទទួលបានវិក្កយបត្រពីអ្នកផ្គត់ផ្គង់។

❖ ជំហានទី២

ការផ្ទៀងផ្ទាត់វិក្កយបត្រទៅអតិថិជន៖ ប្រៀបធៀបរបាយការណ៍ស្តុក និងកំណត់ហេតុដឹកជញ្ជូនទៅនិងគណនីដែលត្រូវទទួល ដើម្បីធានាថាវិក្កយបត្ររបស់អតិថិជនទាំងអស់ត្រូវបានចេញ។ និងកត់ត្រាវិក្កយបត្រណាដែលមិនទាន់បានចេញសម្រាប់ទំនិញដែលបានលក់ហើយ។

❖ ជំហានទី៣

បង្គរចំណាយប្រាក់ឈ្នួលដែលបានបង់៖ កត់ត្រាការចំណាយប្រាក់ឈ្នួលដែលបានកើតឡើងហើយប៉ុន្តែ មិនទាន់បានបង់នៅចុងបញ្ចប់នៃការិយបរិច្ឆេទ។

❖ ជំហានទី៤

គណនា និងកត់ត្រាចំណាយរំលស់៖ គណនានិងកត់ត្រាចំណាយរំលស់សម្រាប់ទ្រព្យសកម្មថេរទាំងអស់ នៅក្នុងបញ្ជីគណនេយ្យ។

❖ ជំហានទី៥

វាយតម្លៃស្តុក៖ ធ្វើការរាប់ស្តុកចុងគ្រា ឬប្រើវិធីសាស្រ្តជំនួសផ្សេងទៀតដើម្បីប៉ាន់ស្មានតម្លៃសមតុល្យចុង គ្រាប្រើព័ត៌មាននេះដើម្បីទាញយកតម្លៃនៃទំនិញដែលបានលក់និងកត់ត្រាទឹកប្រាក់នៅក្នុងកំណត់ត្រា គណនេយ្យ។

❖ ជំហានទី៦

ផ្ទៀងផ្ទាត់សមតុល្យធនាគារ៖ ធ្វើការផ្ទុផ្ទងប្រតិបត្តិការសាច់ប្រាក់នៅធនាគារដែលបានកត់ត្រា ជាមួយ និងរបាយការណ៍នៅធនាគារ។

❖ ជំហានទី៧

ផ្ទេរសមតុល្យពីធនាគារផ្សេងៗ(Subsidiary Ledger )ទៅបញ្ជីធំ( General Ledger)

❖ ជំហានទី៨

ពិនិត្យមើលគណនី៖ ពិនិត្យមើលគណនីតារាងតុល្យការហើយកែតម្រូវសមតុល្យគណនីដើម្បីផ្ទុផ្ទងជាមួយ ព័ត៌មានលម្អិត។

❖ ជំហានទី៩

ធ្វើការពិនិត្យបឋមលើរបាយការណ៍ហិរញ្ញវត្ថុ៖ និងធ្វើការកែតម្រូវសមតុល្យប្រសិនបើមានកំហុស។

❖ ជំហានទី១០

គណនានិងកត់ត្រាពន្ធលើប្រាក់ចំណូល៖ ដោយផ្អែកលើរបាយការណ៍ប្រាក់ចំណូលដែលត្រឹមត្រូវ។

❖ ជំហានទី១១

បិទគណនី៖ បិទសមតុល្យទាំងអស់សម្រាប់រយៈពេលនេះហើយបើកវាសម្រាប់រយៈពេលរាយការណ៍ ក្រោយ។

❖ ជំហានទី១២

ចេញរបាយការណ៍ហិរញ្ញវត្ថុ៖ ដោយបោះពុម្ពកំណែចុងក្រោយនៃរបាយការណ៍ហិរញ្ញវត្ថុ និងរៀបចំ កំណត់ចំណាំដែលពន្យល់ពីចំណុចសំខាន់ៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ជាការពិតណាស់ ម្ចាស់អាជីវកម្មមិនអាចចំណាយពេលផ្ទាល់ខ្លួនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយខ្លួនឯងនោះទេ ប៉ុន្តែម្ចាស់អាជីវកម្មត្រូវយល់អំពីរបាយការណ៍ហិរញ្ញវត្ថុ និងសារៈសំខាន់នៃការរៀបចំ របាយកាណ៍នេះដែរ។ បច្ចុប្បន្ននេះមានទីប្រឹក្សាក្រុមហ៊ុនសវនកម្ម និងកម្មវិធីគណនេយ្យជាច្រើនដែលម្ចាស់ អាជីវកម្មអាចប្រើប្រាស់ ដើម្បីជាជំនួយនូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលធានាបាននូវភាពត្រឹមត្រូវ និងជឿទុកចិត្តបាន។ ដូច្នេះដើម្បីគ្រប់គ្រងអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងធានាបាននូវរីកចម្រើនបាន វែងឆ្ងាយម្ចាស់អាជីវកម្មគួរគិតគូររៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងមានលក្ខណៈស្តង់ដា។

### ៣.២.២ លើកស្ទួយការរីកចម្រើន និងការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាមញ្ញ

### ១. ការលើកស្ទួយការរីកចម្រើន

- ការចូលដំណើរការហិរញ្ញវត្ថុ( Financial Inclusion)៖ បង្កើនឱកាសឱ្យប្រជាជនស្ទើរគ្រប់ផ្នែកអាចចូលរួមប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដូចជា អ្នកមានចំណូលទាប អាជីវកម្មធុនតូច និងមធ្យម
- ការវិនិយោគក្នុងបច្ចេកវិទ្យា( Investment in Technology)៖ ដំណើរការសេវាហិរញ្ញវត្ថុត្រូវបំពាក់ដោយបច្ចេកវិទ្យាស្វ័យប្រវត្តិ ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយការចំណាយ
- ការកែសម្រួលបទប្បញ្ញត្តិ(Regulatory Reforms)៖ បណ្ដាញច្បាប់គួរតែមានលក្ខណៈអាចអនុលោមទៅនឹងភាពវិវត្តន៍ដើម្បីអាចគ្រប់គ្រងហានិភ័យនានានិងលើកស្ទួយភាពមានចីរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។

### ២. ការប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុសាមញ្ញ

- ការប្រើប្រាស់ប្រព័ន្ធ Mobile Banking និង FinTech៖ បច្ចេកវិទ្យាហិរញ្ញវត្ថុឌីជីថលដូចជា និងបណ្ដាញ Mobile Banking បានជួយបង្កើនភាពងាយស្រួល និងកាត់បន្ថយការចំណាយលើប្រតិបត្តិការ
- ការរៀនសូត្រអំពីហិរញ្ញវត្ថុ( Financial Literacy)៖ ប្រជាជនគួរតែមានចំណេះដឹងអំពីការគ្រប់គ្រងសាច់ប្រាក់របស់ខ្លួន ដើម្បីជៀសផុតពីបំណុលខ្ពស់ និងការចំណាយខុសឆ្គង
- ការអភិវឌ្ឍប្រព័ន្ធបង់ប្រាក់ឌីជីថល៖ ប្រព័ន្ធបង់ប្រាក់ឌីជីថលជួយ ឱ្យប្រព័ន្ធហិរញ្ញវត្ថុមានភាពសាមញ្ញ កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ និងបង្កើនសុវត្ថិភាព។

### ៣.២.៣ ផ្ដល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធ

### ១. អាជីវកម្ម

- បង្កើនការគ្រប់គ្រងហិរញ្ញវត្ថុ៖ អង្គភាពធុនតូច និងមធ្យមអាចមានប្រព័ន្ធគណនេយ្យល្អ និងច្បាស់លាស់ដែលជួយបង្កើនការគ្រប់គ្រងហិរញ្ញវត្ថុ
- ងាយស្រួលស្វែងរកហិរញ្ញប្បទាន៖ ធនាគារ និងអ្នកវិនិយោគជឿជាក់លើស្ថានភាពហិរញ្ញវត្ថុ ដោយមានរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ
- បង្កើនអតិភាពប្រកួតប្រជែង៖ មានការបង្ហាញប្រព័ន្ធគណនេយ្យច្បាស់លាស់ អាជីវកម្មអាចបែងចែកថវិកាដោយមានប្រសិទ្ធភាព និងមានកំណើនប្រសើរជាងមុន។

### ២. ធនាគារ និងអ្នកផ្ដល់ហិរញ្ញប្បទាន

- បង្កើនភាពជឿជាក់៖ ធនាគារ និងអ្នកបញ្ចូនឥណទានអាចមានទំនុកចិត្តលើស្ថានភាពហិរញ្ញវត្ថុរបស់ SMEs ដោយសារគណនេយ្យមានស្តង់ដាច្បាស់លាស់
- បង្រួមហានិភ័យក្នុងការឱ្យខ្ចីប្រាក់៖ ដោយសារមានការប្រើប្រាស់សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមSMEs អាចបង្ហាញថវិកា និងការចំណាយបានច្បាស់លាស់។

### ៣. រដ្ឋាភិបាល និងអង្គភាពពាក់ព័ន្ធ

- ងាយស្រួលក្នុងការគ្រប់គ្រងពន្ធ៖ រដ្ឋាភិបាលអាចត្រួតពិនិត្យការបង់ពន្ធដោយមានទិន្នន័យគណនេយ្យត្រឹមត្រូវ
- លើកស្ទួយភាពមាននីតិសម្បទាន៖ អង្គភាពមានការគ្រប់គ្រងសៀវភៅគណនេយ្យត្រឹមត្រូវ និងអាចអនុលោមតាមច្បាប់។

**៤. អ្នកវិនិយោគ និងដៃគូអាជីវកម្ម**

- មានព័ត៌មានលម្អិតសម្រាប់ការវិនិយោគ៖ អាចសម្រេចចិត្តលើការវិនិយោគដោយផ្អែកលើទិន្នន័យគណនេយ្យច្បាស់លាស់
- បង្កើនភាពជឿជាក់ក្នុងដំណើរការអាជីវកម្ម៖ ដៃគូអាជីវកម្មអាចដឹងថាអង្គភាពមានការ គ្រប់គ្រងហិរញ្ញវត្ថុបានយ៉ាងមានប្រសិទ្ធភាព។ អ្នកវិនិយោគបច្ចុប្បន្ន និងអ្នកវិនិយោគសក្តានុពល( Presentand Potential Investors)
- អ្នកគ្រប់គ្រងអង្គភាពអាជីវកម្ម ( Manager of Organizations )
- អ្នកផ្គត់ផ្គង់ ( Suppliers )
- អតិថិជន ( Customers )
- និងអ្នកប្រើប្រាស់ផ្សេងៗទៀត ( Other Consumer ) ។

## ៣.៣ សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

ដាក់ស្តែងបើយើងងាកមកមើលអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យ មានអត្ថប្រយោជន៍សម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងការអភិវឌ្ឍ និងគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាពម្យ៉ាងទៀតបានជួយពង្រឹងដល់តម្លាភាពនៃការរាយការណ៍ហិរញ្ញវត្ថុជាសាកល និងផ្តល់ជាបទដ្ឋានមួយច្បាស់លាស់សម្រាប់ការអនុវត្តគណនេយ្យដោយផ្តល់ភាពងាយស្រួល និងមានទំនុកចិត្តសម្រាប់សហគ្រាស និងអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងអស់។ ការកំណត់ឱ្យមានស្តង់ដាគណនេយ្យនេះ នឹងធ្វើឱ្យប្រទេសនានានៅលើពិភពលោកអាចអនុវត្តរួមគ្នា និងការគណនាតួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដូចជាតួលេខដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលជាដើម។ សារៈសំខាន់នៃស្តង់ដាគណនេយ្យមានអត្ថប្រយោជន៍ដូចជា៖

១. បង្កើនទំនុកចិត្តពីអ្នកមានពាក់ព័ន្ធ( Investors, Banks, Government Creditor)

➤ ពាណិជ្ជករ ឬស្ថាប័នមូលនិធិអាចទុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុដែរត្រូវបានរៀបចំតាមស្តង់ដាវាជួយសម្រួលដល់ការទាក់ទាញប្រាក់រៀង ឬការរកដៃគូអាជីវកម្ម។

២. បង្រួមភាពស្មុគស្មាញនៃការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុ

➤ ស្តង់ដាសម្រាប់ SMEs ត្រូវបានបង្កើតឡើងឱ្យសាមញ្ញជាងស្តង់ដាសម្រាប់ក្រុមហ៊ុនធំៗ ដូច្នេះ SMEs អាចអនុវត្តបានងាយស្រួល។

៣. សម្រួលការត្រួតពិនិត្យ និងសវនកម្ម

➤ ការធ្វើសវនកម្មលើក្រុមហ៊ុននឹងកើតមានភាពងាយស្រួលប្រសិនបើមានរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងសាមញ្ញ។

៤. ជួយសម្រេចចិត្តរហ័ស និងមានប្រសិទ្ធភាព

➤ ព័ត៌មានហិរញ្ញវត្ថុដែលត្រឹមត្រូវ អាចជួយម្ចាស់សហគ្រាសក្នុងការធ្វើសេចក្តីសម្រេចអាជីវកម្មយ៉ាងឆាប់រហ័ស និងផ្អែកលើទិន្នន័យពិត។

៥. ជាជំហានសម្រាប់ការទៅរកការចូលទីផ្សារទំនើប

➤ ប្រសិនបើ SMEs ចង់ធ្វើដំណើរការទៅកាន់ក្រុមហ៊ុនមហាជន ឬនាំចេញទៅក្រៅប្រទេស ការមានរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា គឺជាចំណុចដ៏សំខាន់។

- ការអនុវត្តស្តង់ដាគណនេយ្យផ្តល់អត្ថប្រយោជន៍សម្រាប់ក្រុមហ៊ុនរួមមាន៖

ក្រុមប្រឹក្សាជាតិគណនេយ្យជឿជាក់ថាក្រុមហ៊ុនដែលត្រូវបានរៀបចំឡើងសម្រាប់គោលបំណងនេះ បំពេញតម្រូវការរួមរបស់អ្នកប្រើប្រាស់ភាគច្រើន។ នេះគឺដោយសារអ្នកប្រើប្រាស់ស្ទើរតែទាំងអស់នឹងធ្វើការសម្រេចចិត្តឧទារហណ៍៖

ក.សម្រេចចិត្តនៅពេលទិញរក្សាទុក ឬលក់ឧបករណ៍មូលធន

ខ.វាយតម្លៃឱ្យអ្នកគ្រប់គ្រង ឬគណនេយ្យភាពរបស់អ្នកគ្រប់គ្រង

គ.វាយតម្លៃសមត្ថភាពរបស់អង្គភាពដើម្បីឱ្យទូទាត់និងផ្តល់អត្ថប្រយោជន៍ផ្សេងទៀតឱ្យទៅវិនិយោគរបស់ខ្លួន

ឃ.វាយតម្លៃមូលបត្រសម្រាប់ទឹកប្រាក់ដែលត្រូវឱ្យអង្គភាពខ្ចី

ង.កំណត់គោលនយោបាយពន្ធ

ច.កំណត់ប្រាក់ចំណេញ និងភាគលាភដែលអាចបែងចែក

ឆ.រៀបចំ និងប្រើប្រាស់ស្ថិតិចំណូលជាតិ

ជ.គ្រប់គ្រងសកម្មភាពរបស់អង្គភាព។

## ១. ស្តង់ដារួមតែមួយ

ផ្តោតលើការតម្រូវឱ្យសហគ្រាស អនុវត្តដូចគ្នានូវការកត់ត្រាគណនេយ្យដោយស្របតាមក្របខ័ណ្ឌគណនេយ្យពាក់ព័ន្ធផ្សេងៗ។ សហគ្រាសគួរប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវរាល់ការកត់ត្រាគណនេយ្យដែលបានធ្វើឡើងស្របតាមស្តង់ដាដូចៗគ្នា។ នៅពេលដែលការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាតែមួយធ្វើឱ្យភាគីពាក់ព័ន្ធងាយស្រួលក្នុងការពិនិត្យ និងប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនប្រកបដោយទំនុកចិត្ត។

## ២. ការពង្រឹងទំនុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុ

ភាគីដែលពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុនអាចទទួលបានព័ត៌មានអំពីស្ថានភាពក្រុមហ៊ុនបានតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធទាំងនេះអាចធ្វើការសម្រេចចិត្តទៅបានក៏តាមរយៈការបង្ហាញ ឬទិន្នន័យហិរញ្ញវត្ថុដែលក្រុមហ៊ុនបានរៀបចំឡើងផងដែរ។ បន្ថែមពីនេះសក្តានុពលមួយចំនួនធំអាចធ្វើការសម្រេចចិត្តវិនិយោគតាមរយៈការទទួលបានព័ត៌មានពីរបាយការណ៍ហិរញ្ញវត្ថុដូចគ្នា។

## ៣.ការផ្តល់ជាជំនួយសម្រាប់សវនករ

ស្តង់ដាគណនេយ្យបានបញ្ចូលគ្នារាល់គោលនយោបាយច្បាប់ និងបទប្បញ្ញត្តិគណនេយ្យនៅក្នុងទម្រង់សរសេរតែមួយដែលគោលនយោបាយទាំងនោះត្រូវតែអនុវត្តតាម។ ករណីសវនករពិនិត្យឃើញថាគោលនយោបាយទាំងនោះត្រូវបានអនុវត្តន៍តាមត្រឹមត្រូវ សវនករអាចបញ្ជាក់បានថារបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងនោះគឺមានភាពត្រឹមត្រូវ។ ដោយឡែក ករណីការកត់ត្រា ឬការរាយការណ៍គណនេយ្យបានធ្វើឡើងដោយមិនស្របតាមស្តង់ដាដែលមានជាធរមាន សវនករអាចធ្វើការវិនិច្ឆ័យបានថា ទិន្នន័យដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចមានបញ្ហា។

## ៤. អនុលោមភាពតាមបទប្បញ្ញត្តិ

និយ័តកររបស់រាជរដ្ឋាភិបាលបានកំណត់ថាសហគ្រាស ត្រូវតែអនុវត្តតាមស្តង់ដាគណនេយ្យដែលមានជាធរមាន។ ការអនុវត្តតាមស្តង់ដាគណនេយ្យផ្តល់ជាអត្ថប្រយោជន៍ជូនដល់ម្ចាស់អាជីវកម្មច្រើនតាមរយៈការការពារពីកំហុសឆ្គងដែលអាចកើតមានឡើងក្នុងសហគ្រាស។ ជាមួយគ្នានេះដែរការអនុវត្តតាមស្តង់ដាគណនេយ្យ ក៏ជួយពង្រីកនូវតម្លាភាពប្រតិបត្តិការអាជីវកម្មដែលជាកត្តាមួយអាចពង្រឹងដល់ទីផ្សាររបស់ក្រុមសហគ្រាសឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ស្តង់ដាគណនេយ្យសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជាក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) ជានិយ័តកររបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងពង្រឹង និងជំរុញដល់ការអភិវឌ្ឍវិជ្ជាជីវៈគណនេយ្យ និងសវនកម្មព្រមទាំងជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើបេសកកម្មគ្រប់គ្រងការអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្មតាមរយៈការរៀបចំការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃនូវគោលនយោបាយក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។ យោងតាមប្រកាសលេខ ០៦៨ ស.ហ.វ/ប្រ.ក ចុះនៅថ្ងៃទី ៨ ខែមករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើប្រាស់ស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុកម្ពុជាបានចែងថារាល់សហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែអនុវត្តតាមទាំងស្រុងនូវស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិ( IFRS )ដែលចេញដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ ( IASB ) ដោយរួមទាំងការបកប្រែ និងការកែសម្រួលស្តង់ដា។ កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ (NAC) បានចេញសេចក្តីជូនដំណឹងលេខ ០៩៧០៩ ស.ហ.វ-ក.ជ.គស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS)និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម( CIFRS for SMEs )។

បន្ថែមលើនេះយោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ១០១ ស.ហ.វ.ប្រ.ក ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈបានចែងថា៖ "ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវអនុវត្តតាមរបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ ស.ហ.វ/ប្រ.ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី ៨ ខែមករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា ( ស.រ.ហ.ក ) និងសេចក្តីជូនដំណឹងយោងលេខ ០៩៧/០៩ សហវ/ក.ជ.គ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានិងស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs)។ ក្នុងន័យនេះ រាល់សហគ្រាស ដែលមានគោលបំណង ឬចង់បោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែអនុវត្តស្របតាមស្តង់ដា និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតដែលមានជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៣.៣.១ ការរៀបនិងបង្ហាញពីសក្ខីបត្រសម្រាប់សហគ្រាសធុនតូច និងមធ្យម

ការរៀបចំ និងបង្ហាញពីសក្ខីបត្រសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺមានសារៈសំខាន់សម្រាប់អាជីវកម្មឱ្យមានការអភិវឌ្ឍ និងប្រកបដោយភាពជោគជ័យ។ ប្រសិនបើអ្នកចង់រៀបចំសក្ខីបត្រសម្រាប់

សហគ្រាសនោះអ្នកត្រូវតែមានការរៀបចំផែនការជាលក្ខណៈច្បាស់លាស់ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ការធ្វើអាជីវកម្ម។

**១. ការសិក្សាបរិស្ថានទីផ្សារ និងអាជីវកម្ម**

ត្រូវធ្វើការស្រាវជ្រាវទីផ្សារក្នុងតំបន់ ពីស្ថានភាពជាក់ស្តែងដើម្បីស្គាល់ពីការប្រកួតប្រជែងនិងឱកាសថ្មីៗ។ អ្នកគួរតែទទួលបានការអភិវឌ្ឍទំនាក់ទំនងជាមួយភាគីទាំងអស់ដូចជា អតិថិជន អ្នកផ្គត់ផ្គង់ និងសេវាកម្មផ្សេងៗ។

**២. ការរៀបចំផែនការអាជីវកម្ម**

ការបញ្ចេញសក្ខីបត្រដោយកំណត់ចំណុចសំខាន់ៗ នៃគម្រោងអាជីវកម្មនិងផែនការដែលចង់អនុវត្តផែនការនេះគួរតែបង្ហាញពីគោលបំណងនៃសហគ្រាស និងវិធីសាស្ត្រដែលនឹងអនុវត្តដើម្បីសម្រេចគោលបំណងទាំងនេះ។

**៣. កំណត់គ្រាសម្រាប់សក្ខីបត្រនិងគុណភាព**

បញ្ជីទាំងអស់នៃឯកសារ និងប្រភពដែលគាំទ្រទៅនឹងសក្ខីបត្រនេះ(ឧ.បញ្ជីលក់ ឬសញ្ញាអាជីវកម្មដែលធ្វើការផលិត)។

**៤. ការចុះបញ្ជី និងការទទួលការអនុញ្ញាតពីអាជីវកម្ម**

ត្រូវតែធ្វើការចុះបញ្ជីសហគ្រាសជាផ្លូវការដោយប្រើប្រាស់ប្រព័ន្ធដែលមានសុវត្ថិភាព និងគោលការណ៍ប្រតិបត្តិការផ្សេងៗ។

**៥. ការបង្ហាញពីការត្រួតពិនិត្យ និងធនធានហិរញ្ញវត្ថុ**

ដំណើរការត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុ និងធនធានដែលទាក់ទងដើម្បីធានាថាសហគ្រាសអាចអនុវត្តការអភិវឌ្ឍជានិច្ច។

**៦. ការបង្ហាញពីលទ្ធផលដែលអាចទទួលបាន**

សម្រាប់ការបង្ហាញលទ្ធផលគួរតែមានការបញ្ជាក់ពីការប្រើប្រាស់ជាចុងក្រោយនិងការពង្រឹងសេដ្ឋកិច្ចបណ្តាញផ្សេងៗ។

**ក. ការបង្ហាញពីគណនេយ្យកម្ម សម្រាប់សហគ្រាសធុនតូច និងមធ្យម**

ដើម្បីធានាថា វិធីសាស្ត្រគណនេយ្យកម្មមានប្រសិទ្ធភាព និងអាចជួយដល់ការអភិវឌ្ឍឱ្យកាន់តែមានសុវត្ថិភាព។ ខាងក្រោមនេះគឺជាជំហានមួយចំនួនដែលអាចជួយសហគ្រាសធុនតូច និងមធ្យមបាន។

**១. កំណត់គោលបំណង និងគោលការណ៍គណនេយ្យ**

គោលបំណងគណនេយ្យៈ ដើម្បីធានាថា ការបង្ហាញសេចក្តីថ្លែងព័ត៌មានហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងអាចអនុវត្តបាន។ គោលការណ៍គណនេយ្យអនុវត្តការចុះបញ្ជីតាមក្បួនល្អៗ(ក្បួននៃគណនេយ្យគ្រប់គ្រាន់) ដូចជា ការផ្តល់របាយការណ៍ហិរញ្ញវត្ថុ(IFRS, GAAP)។

**២. សៀវភៅគណនេយ្យ និងការចុះបញ្ជីប្រតិបត្តិការហិរញ្ញវត្ថុ**

សហគ្រាសត្រូវតែបង្កើតសៀវភៅគណនេយ្យសម្រាប់ចុះបញ្ជីប្រតិបត្តិការនានាដែលកើតមាន ប្រាក់ចំណូល ចុះបញ្ជីពីការលក់ផលិតផល សេវាកម្ម ឬចំណាយទាំងអស់រួមមានប្រាក់ឈ្នួល គ្រឿងបរិក្ខារ និងការចំណាយផ្សេងៗ។ ទ្រព្យសម្បត្តិ និងបំណុលដំណើរការបញ្ជូនអំពីទ្រព្យសម្បត្តិ និងបំណុលដែលមាន។

## ៣. ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

- សហគ្រាសត្រូវតែបង្កើតរបាយការណ៍ហិរញ្ញវត្ថុដើម្បីបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។
- របាយការណ៍ចំណូលនិងចំណាយៈ បង្ហាញពីប្រាក់ចំណូល និងចំណាយក្នុងរយៈពេលដែលកំណត់។
- របាយការណ៍ទ្រព្យសម្បត្តិ និងបំណុលៈ បង្ហាញពីទ្រព្យសម្បត្តិ និងបំណុលដែលសហគ្រាសមាន។

## ៤. ការគ្រប់គ្រងប្រាក់រង្វាន់

ការផ្សព្វផ្សាយដំណើរការប្រាក់រង្វាន់ៈ សហគ្រាសត្រូវតែមានការគ្រប់គ្រងប្រាក់រង្វាន់ដើម្បីធានាថាមានសមត្ថភាពក្នុងការបង់ប្រាក់ និងការវិនិយោគឱ្យមានប្រសិទ្ធភាព។

## ៥. គណនេយ្យសម្រាប់ការផ្លាស់ប្តូររដ្ឋបាល

បើសហគ្រាសធុនតូច និងមធ្យមមានការផ្លាស់ប្តូរ បញ្ចូលក្រុមហ៊ុន ឬការផ្លាស់ប្តូរ ឯកសារហិរញ្ញវត្ថុគួរត្រូវបានចុះបញ្ជីល្អ។

## ៦. ប្រព័ន្ធត្រួតពិនិត្យ និងការពារ

ដើម្បីធានានូវសុវត្ថិភាព និងភាពត្រឹមត្រូវនៃការបញ្ជូនព័ត៌មានហិរញ្ញវត្ថុសហគ្រាសត្រូវតែមានប្រព័ន្ធត្រួតពិនិត្យ។ ការត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុត្រួតពិនិត្យការចំណាយប្រាក់ជាប់ការបង់ប្រាក់និងវិនិយោគ។ និងត្រូវការកំណត់ប្រព័ន្ធការពារដើម្បីទប់ស្កាត់ការក្លែងបន្លំក្នុងការបង្ហាញ។ ការតាមដានគណនេយ្យប្រើប្រាស់ឧបករណ៍ដូចជាកម្មវិធីគណនេយ្យ ឬប្រព័ន្ធកុំព្យូទ័រដើម្បីធានាព័ត៌មានទាំងអស់ត្រូវបានចុះបញ្ជី។

### ខ.ការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម

របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញដោយត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។ ការបង្ហាញត្រឹមត្រូវទាមទារនូវការបង្ហាញប្រកបដោយការពិតអំពីឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍ និងស្ថានការណ៍ដទៃទៀត ស្របតាមនិយមន័យ និងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់សម្រាប់ ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដូចបានចែងនៅក្នុងផ្នែកទី២ ស្តីពីទស្សនទាន និងគោលការណ៍ទូទៅ។

ការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យមរួមជាមួយ ការលាតត្រដាងបន្ថែមបើមានការចាំបាច់ ត្រូវបានសន្មតថានាំឱ្យមានរបាយការណ៍ហិរញ្ញវត្ថុ ដែលសម្រេចបានការបង្ហាញត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពធុនតូច និងមធ្យម។ ការអនុវត្តស្តង់ដានេះដោយអង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈមិននាំឱ្យមានការបង្ហាញត្រឹមត្រូវ ស្របតាមស្តង់ដានេះទេ។ ការលាតត្រដាងបន្ថែមដែលមានចែងក្នុងចំណុចចាំបាច់ត្រូវធ្វើនៅពេលដែលអនុលោមតាមការតម្រូវពិសេសនានាក្នុងស្តង់ដានេះនៅតែមិនគ្រប់គ្រាន់សម្រាប់ឱ្យអ្នកប្រើប្រាស់អាចយល់អំពីឥទ្ធិពលនៃប្រតិបត្តិការពិសេសដោយឡែកនានាព្រឹត្តិការណ៍និងស្ថានការណ៍ដទៃទៀតលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់អង្គភាព។

របាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ គឺជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដំបូងដែលអង្គភាពត្រូវធ្វើការថ្លែងការណ៍ច្បាស់លាស់ និងឥតលាក់លៀមចំពោះរបាយការណ៍ហិរញ្ញវត្ថុទាំងនោះដែលអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូច និងមធ្យម។

**៣.៣.២.អត្ថប្រយោជន៍នៃការអនុវត្តស្តង់ដាក្នុងSMEs**

ការអនុវត្តស្តង់ដាក្នុងអាជីវកម្មតូច និងមធ្យមមានអត្ថប្រយោជន៍ជាច្រើនសម្រាប់ការអភិវឌ្ឍ និងការរីកចម្រើនរបស់អាជីវកម្ម។ អត្ថប្រយោជន៍សំខាន់ៗរួមមាន៖

ការអនុវត្តស្តង់ដានៅក្នុង SMEs មានសារៈសំខាន់ខ្ពស់ក្នុងការបង្កើនគុណភាពផលិតផល កែលម្អដំណើរការផលិតបង្កើនភាពជឿជាក់ពីអតិថិជន និងបង្កើនលទ្ធភាពក្នុងការចូលទៅកាន់ទីផ្សារថ្មី។ SMEs ដែលអនុវត្តស្តង់ដា អាចមានលទ្ធភាពប្រកួតប្រជែងខ្ពស់ និងទទួលបានការរីកចម្រើនយូរអង្វែង។

**៣.៣.៣. ការគ្រប់គ្រងរបាយការណ៍សម្រាប់SMEs**

ការគ្រប់គ្រងរបាយការណ៍សម្រាប់អង្គភាពធុនតូច និងមធ្យម គឺមានសារៈសំខាន់ក្នុងការជួយឱ្យមានការត្រួតពិនិត្យ និងគ្រប់គ្រងល្អលើសកម្មភាពផ្នែកហិរញ្ញវត្ថុការលក់ និងប្រព័ន្ធផ្សេងៗ។ វាអាចរួមបញ្ចូលធាតុផ្សេងៗដូចជា៖

**១. របាយការណ៍ហិរញ្ញវត្ថុ**

- របាយការណ៍ប្រាក់ចំណូល និងចំណាយ (Profit and Loss Statement)
- របាយការណ៍ទីផ្សារ និងផ្នែកផ្គត់ផ្គង់ (Balance Sheet)
- របាយការណ៍សាច់ប្រាក់ ( Cash Flow Statement)

**២. ការប្រមូលព័ត៌មាន**

- កំណត់ត្រាការលក់ និងទិញ
- កំណត់ត្រាផលិតផល និងសេវាកម្ម

**៣. ការប្រើប្រាស់សង្ខេបបច្ចេកវិទ្យា**

ការប្រើប្រាស់កម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុ ឬ ERP (Enterprise Resource Planning) ដើម្បីធ្វើឱ្យការងារលឿន និងមានប្រសិទ្ធភាព

**៤. ការប្រមូលមតិយោបល់ និងការវិភាគ**

វិភាគលទ្ធផល និងបញ្ហាផ្សេងៗក្នុងការប្រកួតប្រជែង

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ

ជាទូទៅការវិភាពលើចំណុចខ្លាំង និងចំណុចខ្សោយលើសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមមានសារៈសំខាន់បំផុតក្នុងការរៀបចំ កត់ត្រា និងប្រើប្រាស់ព័ត៌មានហិរញ្ញវត្ថុ ដើម្បីធានាបាននូវភាពត្រឹមត្រូវ តាមបទដ្ឋានច្បាប់ និងភាពជឿជាក់។

ហេតុនេះបន្ទាប់ពីក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវរួចមក និងវាយតម្លៃបានថាសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមយើងខ្ញុំបានសង្កេតឃើញថានូវមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម។

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រោយពីបានសិក្សាស្រាវជ្រាវ និងវិភាគទៅលើតួនាទីនិយ័តករគណនេយ្យនិងសវនកម្ម របស់ស្តង់ដាគណនេយ្យ និងសវនកម្មសម្រាប់សហគ្រាសធុនតូច  និងមធ្យមរួចមកយើងសង្កេតឃើញថានិយ័តករគណនេយ្យនិងសវនកម្មជាស្ថាប័ននិយ័តករដែលមានសមត្ថភាព និងគុណតម្លៃវិជ្ជាជីវៈព្រមទាំងមានកិច្ចដំណើរការប្រកបដោយនិរន្តភាពនិងគណនេយ្យភាព ដោយទទួលបាននូវការទុកចិត្តពីរាជរដ្ឋាភិបាល វិស័យឯកជន និងតួអង្គពាក់ព័ន្ធ។ដូចនេះ ទើបក្រុមនាងខ្ញុំពិនិត្យឃើញនូវចំណុចខ្លាំងដូចខាងក្រោម៖

- ជួយពង្រឹងដល់តម្លាភាពនៃការរាយការណ៍ហិរញ្ញវត្ថុជាសាកល
- ជួយឱ្យអង្គភាពអាចរៀបចំរបាយការណ៍គណនេយ្យភាពសាមញ្ញ និងភាពជឿជាក់
- បង្កើនទំនុកចិត្តពីអ្នកមានពាក់ព័ន្ធ Investors Banks  Government and Creditors
- ការពង្រឹងទំនុកចិត្តលើរបាយការណ៍ហិរញ្ញវត្ថុដែលជាជំហានសម្រាប់ការចូលរួមនៅលើទីផ្សារអន្តរជាតិ
- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាតែមួយធ្វើឱ្យភាគីពាក់ព័ន្ធងាយស្រួលក្នុងការពិនិត្យ និងប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនប្រកបដោយទំនុកចិត្ត
- ជួយឱ្យសហគ្រាសមានរបាយការណ៍គណនេយ្យមានស្តង់ដាស្របតាមច្បាប់ និងងាយស្រួលក្នុងការត្រួតពិនិត្យពីក្រសួងពាក់ព័ន្ធ
- ស្តង់ដានេះត្រូវបានរចនាឡើងឱ្យសមស្របនឹងសហគ្រាសធុនតូច និងមធ្យមដែលមិនមានប្រព័ន្ធគ្រប់គ្រងស្មុគស្មាញ
- ត្រូវបានទទួលស្គាល់អន្តរជាតិ (IFRS for SMEs) ហើយមានការសម្រួលឱ្យសមស្របនឹងស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកក្នុងប្រទេសជាច្រើន
- ការប្រើស្តង់ដាគណនេយ្យត្រឹមត្រូវអាចបង្កើនទំនុកចិត្តពីភាគីទីបីដូចជាធនាគារ អ្នកវិនិយោគ និងសហការីពាណិជ្ជកម្ម
- ស្ថាប័ន NAC ឬIFRS  for SMEs បានផ្តល់នូវស្តង់ដាគណនេយ្យសម្រាប់ឱ្យសហគ្រាសធុនតូច  និងមធ្យមអាចអនុវត្តបាន។
- ត្រូវអនុលោមតាមបទប្បញ្ញត្តិដែលនិយ័តកររបស់រាជរដ្ឋាភិបាលបានកំណត់

## ៤.២ ការវិភាគលើចំណុចខ្សោយ

ចំណុចខ្សោយរបស់សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូចនិងមធ្យមៈ

- សហគ្រាសធុនតូច និងមធ្យមជាច្រើន ខ្វះលទ្ធភាពទទួលបានវគ្គបណ្តុះបណ្តាលត្រឹមត្រូវ
- ស្តង់ដាមានពាក្យបច្ចេកទេស ឬចំណុចជាច្រើនដែលអាចបង្កការយល់ច្រឡំនៅពេលអនុវត្ត
- ការចំណាយពេលវេលា និងថវិកាការអនុវត្តស្តង់ដាអាចបន្ថែមផ្នែកការងារ និងការចំណាយសម្រាប់ SMEs
- ស្តង់ដាមានលក្ខណៈទូទៅ ដែលមិនត្រូវទៅ នឹងស្ថានភាពជាក់លាក់របស់អាជីវកម្មខ្លះ
- បុគ្គលិកជាច្រើនមិនមានអ្នកជំនាញគ្រប់គ្រាន់ក្នុងការបំពេញតាមស្តង់ដា

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍

## ៥.១ ការសន្និដ្ឋាន

សរុបសេចក្តីមកបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទដែលនិយាយពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម និងដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរួចមក យើងអាចសន្និដ្ឋានបានថា គ្រប់អង្គភាពបានរៀបចំប្រព័ន្ធគ្រប់គ្រង នីតិវិធីត្រួតពិនិត្យ និងវិធីសាស្ត្រក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបានយ៉ាងត្រឹមត្រូវតាមច្បាប់នៃស្តង់ដាគណនេយ្យ។ ស្របទៅតាមសេចក្តីសន្និដ្ឋាននេះសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺជាឧបករណ៍សំខាន់មួយសម្រាប់ធានាថា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុវត្តទៅតាមគោលការណ៍សម្គាល់ និងមានភាពជាក់ស្តែង។ សារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមមានសារៈសំខាន់គឺជួយបង្កើនភាពជឿជាក់ និងតម្លាភាព នៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសមានភាពច្បាស់លាស់ និងអាចទុកចិត្តបានចំពោះភាគីពាក់ព័ន្ធដូចជា ធនាគារ អ្នកវិនិយោគ រាជរដ្ឋាភិបាល។ ជាពិសេសក៏ជានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តជាក់ស្តែងសម្រាប់សហគ្រាសដែលមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយភាពវិជ្ជាជីវៈច្បាស់លាស់ និងងាយក្នុងការសម្រេចចិត្តខាងផ្នែកហិរញ្ញវត្ថុបានប្រសើរឡើង។ មិនតែប៉ុណ្ណោះសារៈសំខាន់នៃស្តង់ដាគណនេយ្យ ក៏បានសម្រួលដល់សហគ្រាសធុនតូច និងមធ្យមងាយស្រួលក្នុងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលត្រឹមត្រូវ ទើបសហគ្រាសអាចមានឱកាសទាក់ទាញបាននូវមូលនិធិ និងជំនួយពីធនាគារ ឬអ្នកវិនិយោគជាច្រើនបានងាយស្រួលម្យ៉ាងវិញទៀតការអនុវត្ត ស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមសហគ្រាសទាំងអស់ត្រូវអនុលោមតាមច្បាប់ដែលនិយ័តករបានកំណត់ និងការប្រកាសពន្ធបានយ៉ាងត្រឹមត្រូវទើបការអនុវត្តស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមកម្ពុជាចំពោះសហគ្រាសមានប្រសិទ្ធភាព។

ដូចនេះនៅក្នុងសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមគឺពិតជាមានសារៈសំខាន់យ៉ាងខ្លាំងណាស់ក្នុងការធានាលើ ការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព តម្លាភាព និងជួយបង្កើនភាពជឿជាក់ចំពោះសាធារណជនអ្នកវិនិយោគបណ្តាក់ទុន ដែលអនុវត្តលើស្តង់ដានេះបានយ៉ាងត្រឹមត្រូវផងដែរ និងឈានទៅរកភាពរីកចម្រើនយ៉ាងខ្លាំង ហើយក៏មានឱកាសក្នុងការចូលរួមប្រកួតប្រជែងគ្នានៅលើទីផ្សារអន្តរជាតិជាពិសេសបានជួយជម្រុញដល់សេដ្ឋកិច្ចជាតិក្នុងប្រទេសកម្ពុជាមានភាពរីកចម្រើន និងជាចំណែកនៃលំហូសាច់ប្រាក់ដែលអាចទ្រទ្រង់ដល់ឆ្អឹងខ្នងសេដ្ឋកិច្ចនៅក្នុងប្រទេសយ៉ាងរឹងមាំផងដែរ។

## ៥.២ ការផ្តល់អនុសាសន៍

ឆ្លងកាត់តាមការស្រាវជ្រាវអំពីសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម

- ថ្វីត្បិតតែសារៈសំខាន់នៃស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមបានដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុក៏ដោយ តែអង្គភាពគួរតែយកចិត្តទុកដាក់លើបុគ្គលិកដែលមិនទាន់យល់ច្បាស់ពីស្តង់ដាគណនេយ្យ
- ខ្វះការបណ្តុះបណ្តាល និងបុគ្គលិកជំនាញៗ ជាច្រើនជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍមិនត្រូវខ្វះលទ្ធភាពចូលរួមវគ្គបណ្តុះបណ្តាលនោះទេ។ ជាពិសេសទោះបីជាស្តង់ដាគណនេយ្យសម្រាប់កម្ពុជាត្រូវបានបកប្រែមកពីស្តង់ដាអន្តរជាតិក៏ដោយប៉ុន្តែសម្រាប់សហគ្រាសអាជីវកម្មដែលស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍ គឺត្រូវមានវិធានការលើការបណ្តុះបណ្តាលធនធានគណនេយ្យឱ្យមានជំនាញទើបការអនុវត្តស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យមអាចទទួលស្គាល់ជាធរមាន
- ការបំពានលើលក្ខខណ្ឌប្រើប្រាស់ IFRS for SMEs អង្គភាពមិនអាចប្រកាសថាខ្លួនអនុលោមតាម IFRS for SMEs ទេប្រសិនបើមិនបានបំពេញលក្ខខណ្ឌសមរម្យនៃស្តង់ដា
- ភាពលំអៀងក្នុងការរៀបចំរបាយការណ៍៖ ដោយសារគ្មានស្តង់ដាដែលគ្រប់គ្នាអនុវត្តដូចគ្នា បណ្តាលឱ្យមានភាពលំអៀងនៃព័ត៌មានហិរញ្ញវត្ថុ។

## ឯកសារយោង


1. គី សុភាក់. (ថ្ងៃ០៨ ខែមេសា ២០២៥). *ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ*. ទស្សនាវដ្ដីវិទ្យាសាស្ត្រលេខ៤នៃសាកលវិទ្យាល័យវ៉ាន់ដា.ទំព័រ៥ ដល់៦
2. គី សុភាក់. (ថ្ងៃ០៨ ខែមេសា ២០២៥). *ការអភិវឌ្ឍនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ*. ទស្សនាវដ្ដីវិទ្យាសាស្ត្រលេខ៤ នៃសាកលវិទ្យាល័យវ៉ាន់ដា.ទំព័រ៤ ដល់២
3. និយ័តករគណនេយ្យ និងសវនកម្ម. (ឆ្នាំ២០១៥). *IFRS for SMEs*. ផ្នែកទី៣. ទំព័រទី២១. ២៩២ទំព័៥។
4. វិទ្យាស្ថាន វ៉ាន់ដា. (បោះពុម្ពឆ្នាំ២០១៣). ផ្នែកទី១១ ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិឆ្នាំ២០០៩ ទំព័រ ១២៣ ដល់ ១២៥
5. វិទ្យាស្ថាន វ៉ាន់ដា. (២០២៤). *សវនកម្ម (Auditing) ភាគ១*. បោះពុម្ពលើកទី១១. ទំព័រទី៨. ភ្នំពេញ
6. KHsearch. គណនេយ្យ. (2019, March 28). *មេរៀនទស្សនៈទានទូទៅអំពីគណនេយ្យ(ភាគ១)*. Retrieved March, 02 2025 from https://www.khsearch.com/qna/18013
7. អង្គភាពសវនកម្មផ្ទៃក្នុង. (២០២៤). *ការគ្រប់គ្រងហិរញ្ញវត្ថុ*. Retrieved March, 03 2025 from https://iauoffsa.gov.kh/wp-content/uploads/2024/
8. និយ័តករគណនេយ្យនិងសវនកម្ម (2015). *ត្រង់ផ្នែកទី២ទំព័រទី៩*. Retrieved March, 03 2025 from https://www.acar.gov.kh/
9. ធនាគាជាតិនៃកម្ពុជា. (ឆ្នាំ២០២១). *រៀបចំដោយសោសុន្ទរ៍ធារី.* ទំព័រទី៧. Retrieved March, 03 2025 from https://www.nbc.gov.kh/
10. អង្គភាពសាវនករផ្ទៃ. រៀបចំដោយលោក ឡាំ ស៊ីនឿន.(ខែមេសា ឆ្នាំ២០២៤). *IFRS for SMEs*. Retrieved March, 05 2025 from https://search.app/vzbQ5daGg2BNYWKfA
11. អង្គភាពសាវកម្មផ្ទៃក្នុង. (ឆ្នាំ២០២៤). *សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ*. ត្រង់ទំព័រទី៥ និងទី៦. Retrieved March, 03 2025 from https://search.app/tQbYHLjXZ52DHoK47

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១



## ឧបសម្ព័ន្ធទី២


គណនេយ្យ
ទស្សនាវដ្ដីវិទ្យាសាស្ត្រ
SCIENCE MAGAZINE
VIA.010.171
Library/2023
លេខទី១ ២០២៣

# ឧបសម្ព័ន្ធទី៣


2009
ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)
របាយការណ៍ហិរញ្ញវត្ថុគំរូសម្រាប់សហគ្រាសធុនតូច និងមធ្យម
Illustrative Financial Statement for SMEs
Cambodian International Financial Reporting Standards
for Small and Medium-Sized Entities
IFRS

**ឧបសម្ព័ន្ធទី៤**


វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ១
Auditing
សវនកម្ម
រក្សាសិទ្ធិគ្រប់យ៉ាងដោយ វិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី១០(២០២៣)
សម្រាប់ប្រើប្រាស់ផ្ទៃក្នុង

**ឧបសម្ព័ន្ធទី៥**



You Tube
និយ័តករគណនេយ្យនិងសវនកម្ម
ACCOUNTING AND AUDITING REGULATOR

## ឧបសម្ព័ន្ធទី៦




អត្ថបទផ្សព្វផ្សាយប្រចាំខែកុម្ភៈ ឆ្នាំ២០២៤ អង្គភាពសវនកម្មផ្ទៃក្នុង Retrieved March, 03 2025 from https://iauoffsa.gov.kh/wp-content/uploads/2024/

## ឧបសម្ព័ន្ធទី៧



ឧបសម្ព័ន្ធទី៨


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
អង្គភាពសវនកម្មផ្ទៃក្នុង
ឧត្តមានុវត្តន៍
នៃការគ្រប់គ្រងហិរញ្ញវត្ថុ
ឆ្នាំ២០២៤
THE IMPORTANCE OF
FINANCIAL
MANAGEMENT